អង្គការសហប្រជាជាតិ
A/HRC/24/32

# មហាសន្និបាត

ចែកចាយ : ទូទៅ
២៤ មិថុនា ២០១៣

អត្ថបទដើម ៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីម្ភៃបួន**
របៀបវារៈចំណុច ១០
**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

## តួនាទី និង សមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយឧបត្ថម្ភដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកស្ទួយ និង ការពារសិទ្ធិមនុស្ស*

**របាយការណ៍របស់អគ្គលេខាធិការ**

*សង្ខេប*

របាយការណ៍នេះ ត្រូវបានដាក់ជូនស្របតាមសេចក្តីសម្រេចលេខ១៨/២៥ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលក្នុងនោះក្រុមប្រឹក្សាសិទ្ធិមនុស្ស បានស្នើឲ្យអគ្គលេខាធិការរាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស នាសម័យប្រជុំលើកទីម្ភៃបួនរបស់ខ្លួន ស្តីពីតួនាទី និង សមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។

* ការដាក់ជូនយឺតពេល

GE. 11-

មាតិកា


| | | កថាខណ្ឌ | ទំព័រ |
|---|---|---|---|
| I. | សេចក្តីផ្តើម | ១-៨ | ៣-៤ |
| II. | សិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន | ៩-២០ | ៤-៧ |
| III. | នីតិរដ្ឋ | ២១-៣៤ | ៨-១១ |
| IV. | គាំទ្រកំណែទម្រង់ពន្ធនាគារ | ៣៥-៤៤ | ១២-១៤ |
| V. | សេរីភាពជាមូលដ្ឋាន និងសង្គមស៊ីវិល | ៤៥-៥២ | ១៥-១៧ |
| VI. | ទំនាក់ទនងសាធារណៈ និងការងារតស៊ូមតិ | ៥៣-៥៩ | ១៧-១៨ |
| VII. | ស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេស និងការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ | ៦០-៦២ | ១៩-១៩ |

**I.សេចក្តីផ្តើម**

១. របាយការណ៍នេះដាក់ជូនតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ ១៨/២៥។ របាយការណ៍នេះ រៀបរាប់ពីសកម្មភាពរបស់ការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា(ការិយាល័យ OHCHR) ក្នុងអំឡុងពេលចាប់ពីខែ កក្កដា ឆ្នាំ ២០១២ ដល់ ខែ ឧសភា ឆ្នាំ ២០១៣។ ការរៀបចំរបាយការណ៍នេះត្រូវបានបញ្ចប់នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៣។

២. វត្តមានរបស់ការិយាល័យ OHCHR ដែលផ្តល់អាណត្តិដោយគណៈកម្មការសិទ្ធិមនុស្សតាមសេចក្តី សម្រេចលេខ ១៩៩៣/៦ បានបន្តផ្តល់ជំនួយដល់រដ្ឋាភិបាល និង ប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ និង គោរពសិទ្ធិមនុស្សនៅក្នុងវិស័យសំខាន់ៗចំនួន ៥ ដូចជា កំណែទម្រង់ពន្ធនាគារ សេរីភាពជា មូលដ្ឋាន សិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន នីតិរដ្ឋ និង លើកកម្ពស់កេរដំណែលរបស់អង្គជំនុំជម្រះ វិសាមញ្ញ ក្នុងតុលាការកម្ពុជា (អវតក)។ ការងាររបស់ការិយាល័យនេះក៏ពង្រីកផងដែរ ដល់បញ្ហាធុរកិច្ច និងសិទ្ធិមនុស្ស។

៣. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ សហប្រតិបត្តិការបានពង្រឹង និងពង្រីកជាមួយដៃគូរដ្ឋាភិបាលសំខាន់ៗមួយចំនួន ជាពិសេសបំផុត ជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ (រួមទាំង អគ្គនាយកដ្ឋានពន្ធនាគារ) និង រដ្ឋបាលរាជធានី ខេត្តមួយចំនួន។ ក្រៅពីនេះ ទំនាក់ទំនងសហប្រតិបត្តិការត្រូវបានបង្កើតឡើង (ឬ ត្រូវបានបន្ត) ជាមួយស្ថាប័នរដ្ឋាភិបាលផ្សេងទៀត រួមទាំងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អង្គភាពប្រឆាំងអំពើពុករលួយ និងក្រសួងបរិស្ថាន។ តំណាងរដ្ឋាភិបាលនៅលំដាប់ថ្នាក់ផ្សេងៗគ្នា បានសំដែងការពេញចិត្ត និងវាយតម្លៃខ្ពស់ ដល់ការិយាល័យ OHCHR ដែលបានផ្តល់ជំនួយបច្ចេកទេស។ សហប្រតិបត្តិការជាមួយស្ថាប័ន តុលាការត្រូវបានពង្រីកយ៉ាងខ្លាំង (រួមទាំងជាមួយ អវតក) និង សហប្រតិបត្តិការជាមួយទំនាក់ទំនង ជាមួយរដ្ឋសភា និង ព្រឹទ្ធសភាត្រូវបានពង្រឹង។ នៅឆ្នាំ ២០១២ ការិយាល័យបានខិតខំពង្រីកឥទ្ធិពល ការងាររបស់ខ្លួនកាន់តែជិតស្និទ្ធថែមទៀតជាមួយស្ថាប័នផ្សេងទៀងរបស់អង្គការសហប្រជាជាតិប្រចាំ ប្រទេសកម្ពុជា។

៤. អគ្គលេខាធិការមានជំនឿថា ឧត្តមស្នងការទទួលលបន្ទុកសិទ្ធិមនុស្សប្តេជ្ញាបន្តផ្តល់ជំនួយគាំទ្រដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការពង្រឹងការការពារ និង លើកកម្ពស់សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ហើយសង្ឃឹមថា អនុស្សរណៈនៃការយោគយល់ ដែលមានរយៈពេល ២ ឆ្នាំ ស្តីពីជំនួយបច្ចេកទេសរវាងការិយាល័យ OHCHR និង រាជរដ្ឋាភិបាលនឹងត្រូវបន្តហួសពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣។

៥. ការិយាល័យ OHCHR ក៏បានបន្តគាំទ្រការងាររបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា លោកសូរិយា ស៊ូប៊ែឌី ដែលបានធ្វើដំណើរទស្សនកិច្ចនៅប្រទេសកម្ពុជានៅខែ ធ្នូ ឆ្នាំ ២០១២ និង នៅខែ ឧសភា ឆ្នាំ ២០១៣ នៅក្នុងអំឡុងពេលនៃវដ្តធ្វើរបាយការណ៍។ អគ្គលេខាធិការមានការព្រួយបារម្ភអំពីការវាយប្រហារជាបុគ្គលទៅលើបូរណភាពរបស់អ្នករាយការណ៍ពិសេស ក្នុងនោះរួមមានការវាយប្រហារពីតំណាងរដ្ឋាភិបាលផងដែរ និងជំរុញអោយរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធទាំងអស់ សហការជាមួយអ្នករាយការណ៍ពិសេសយ៉ាងពេញលេញក្នុងការងាររបស់លោក ដូចបានបញ្ជាក់ក្នុងរបាយការណ៍ (A/HRC/២៤/៥៤) របស់អ្នករាយការណ៍ពិសេស។

៦. កំណត់ត្រាដ៏ល្អរបស់ប្រទេសកម្ពុជាក្នុងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស ត្រូវបានពង្រឹងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ។ ការិយាល័យ OHCHR មានសេចក្តីរីករាយក្នុងការជួយដំណើរការនេះនៅថ្នាក់ជាតិ។ ការិយាល័យ OHCHR ក៏អាចគាំទ្ររដ្ឋាភិបាលក្នុងការជម្រះការកកស្ទះនៃរបាយការណ៍ហួសពេលកំណត់សម្រាប់ដាក់ជូនគណៈកម្មការសន្ធិសញ្ញា ហើយបន្តគាំទ្រក្នុងការរៀបចំសេចក្តីព្រាង

របាយការណ៍លើកក្រោយៗដែលដល់កំណត់តាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ ការគាំទ្រត្រូវបានធ្វើឡើងដើម្បីតាមឃ្លាំមើលការអនុវត្តអនុសាសន៍ចំនួន ៩១ ដែលប្រទេសកម្ពុជាបានទទួលយកនៅក្នុងអំឡុងពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់លើកដំបូង ក៏ដូចជាការរៀបចំសម្រាប់ការពិនិត្យលើកទី ២ នៅដើមឆ្នាំ ២០១៤។ ការគាំទ្រនេះក៏បានពង្រីកទៅដល់ក្រុមសង្គមស៊ីវិលដែលចង់ផ្តល់របាយការណ៍ និង ដល់ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីដំណើរការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ការិយាល័យមានការចូលរួមពីអ្នកផ្តល់ជំនួយមួយចំនួន។

៧. ក្រៅពីការគាំទ្របច្ចេកទេសដល់រដ្ឋាភិបាល និង សង្គមស៊ីវិល ការិយាល័យបានឃ្លាំមើលរឿងក្តីមួយចំនួនទាក់ទងនឹងសិទ្ធិមនុស្ស។ ចំនួន និងប្រភេទរឿងក្តីដែលការិយាល័យ OHCHR បានធ្វើអន្តរាគមន៍ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងអំឡុងពេលធ្វើរបាយការណ៍ពីមុន (A/HRC/២១/៣៥)។ ការិយាល័យ OHCHR មានបំណងធ្វើការជាមួយអាជ្ញាធរ សង្គមស៊ីវិល សហគមន៍ និង បុគ្គល ដើម្បីចៀសវាងអំពើហិង្សា ទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស ឬ បញ្ឈប់អំពើហិង្សាដែលកំពុងបន្តកើតឡើង។ នៅក្នុងរឿងក្តីមួយចំនួន ការិយាល័យ OHCHR គឺជាតួអង្គមួយក្នុងចំណោមតួអង្គមួយចំនួនដែលមានវត្តមាន និង អាចជួយបំពេញតួនាទីការពារសិទ្ធិមនុស្ស។

៨. ការងាររឿងក្តីបុគ្គលរបស់ការិយាល័យបន្តផ្តោតទៅលើទំនាស់ពាក់ព័ន្ធទៅនឹងដីធ្លី ការកម្រិតទៅលើសេរីភាពនៃការបញ្ចេញមតិ សិទ្ធិទទួលបានជម្រះក្តីដោយយុត្តិធម៌ ការឃុំខ្លួនដោយបំពាន និង ល័ក្ខខ័ណ្ឌឃុំខ្លួន រួមទាំងការធ្វើបាប។ ទំនាស់ពាក់ព័ន្ធទៅនឹងដីធ្លីបន្តជាបញ្ហាប្រឈមដ៏សំខាន់សម្រាប់ប្រទេសនេះ។ ខណៈពេលគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដ៏ធំបានធ្វើឡើងនៅក្នុងឆ្នាំ ២០១២ ដោយមានការចែកប័ណ្ណកម្មសិទ្ធិដល់គ្រួសារនៅជនបទជាច្រើននោះ ទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃមួយចំនួននៅតែកើតមានឡើង។ ការិយាល័យបានឃ្លាំមើល និង អន្តរាគមន៍នៅក្នុងរឿងបាតុកម្ម ការតវ៉ា ការបំភិតបំភ័យ ការឃុំខ្លួន និង នីតិវិធីតុលាការ ដែលកើតឡើងចេញពីទំនាស់ទាំងនេះ។ ការិយាល័យក៏បានតស៊ូមតិផងដែរអំពីសិទ្ធិ សេរីភាពបញ្ចេញមតិរបស់ប្រជាជនកម្ពុជា រួមទាំងអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និង អ្នកសហជីព។ ការចោទប្រកាន់អំពីការរិតត្បិត ដែលពុំត្រូវបានអនុញ្ញាត អំពីសេរីភាពបញ្ចេញមតិក្នុងអំឡុងពេលកិច្ចប្រជុំកំពូលពាក់ព័ន្ធនឹងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានលើកឡើងជាមួយអាជ្ញាធរ។ នៅក្នុងផ្នែកសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ ការិយាល័យបានពិនិត្យឃ្លាំមើលនីតិវិធីតុលាការមួយចំនួន រួមទាំងរឿងក្តីរបស់តស្សូរជនធំៗផងដែរ។ នៅក្នុងករណីខ្លះ ការិយាល័យបានធានាការការពារក្តីដល់ចុងចោទ។ ដោយកសាងការគាំទ្រដល់រដ្ឋាភិបាលក្នុងការដោះស្រាយភាពខ្វះខាតក្នុងការការពារសិទ្ធិមនុស្សក្នុងរឿងឃុំខ្លួនបុគ្គល ការិយាល័យ OHCHR ក៏បានយកចិត្តដាក់ជាប្រព័ន្ធទៅនឹងអាជ្ញាធរក្នុងរឿងការឃុំខ្លួនដោយបំពាន និង ការធ្វើបាប ដែលបង្កើតឲ្យមានលទ្ធផលជាទីពេញចិត្តជាច្រើនរួមទាំងករណីដោះលែងផងដែរ។

## II.សិទ្ធិដីធ្លី និង សិទ្ធិលំនៅឋាន

៩. កម្មវិធីសិទ្ធិដីធ្លី និង សិទ្ធិលំនៅឋានរបស់ការិយាល័យ OHCHR ធ្វើការជាមួយរដ្ឋាភិបាល អង្គការសង្គមស៊ីវិល សហគមន៍ បុគ្គល សហគ្រាសអាជីវកម្ម សមាគមវិជ្ជាជីវៈ ព្រមទាំងជាមួយតួអង្គអភិវឌ្ឍន៍ពហុភាគី និង ទ្វេភាគី ដើម្បីពង្រឹងក្របខ័ណ្ឌគតិយុត្តដែលការពារការប្រើប្រាស់ និង កម្មសិទ្ធិលើដីធ្លី និង សិទ្ធិលំនៅឋាន និងដើម្បីពង្រឹងការអនុវត្ត។ កម្មវិធីនេះក៏ធ្វើការជាមួយបុគ្គល សហគមន៍ និង អាជ្ញាធរ ពាក់ព័ន្ធនឹងករណីគម្រាមកំហែង រំខាន និង ការធ្វើទុក្ខបុកម្នេញផ្នែកព្រហ្មទណ្ឌទៅលើបុគ្គល និង សហគមន៍ ដែលធ្វើសកម្មភាពការពារសិទ្ធិដីធ្លី និង សិទ្ធិលំនៅឋានរបស់គេ ព្រមទាំងជាមួយអ្នកការពារសិទ្ធិមនុស្សដែលធ្វើការលើបញ្ហាដីធ្លី។

១០.	ការិយាល័យ OHCHR ធ្វើប្រតិបត្តិការនៅក្នុងបរិបទទំនាស់ដីធ្លីកំពុងកើតឡើងទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង។ ខណៈពេលមានការផ្លាស់ប្តូរបន្តិចបន្តួចក្នុងការដោះស្រាយទំនាស់ ឬ ការបង្កើនការធានាសិទ្ធិកាន់កាប់ដីធ្លីក្នុងតំបន់ទីក្រុងភាគច្រើន នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើយុទ្ធនាការសំខាន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់បុគ្គលឯកជនទាំងក្នុង និង ជុំវិញសម្បទានដីសេដ្ឋកិច្ច សម្បទានកាប់ឈើ និង តំបន់ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ព្រមទាំងដីរដ្ឋដែលត្រូវបានរឹបអូស ដែលស្ថិតនៅក្រោមការជួយគាំទ្រពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យុទ្ធនាការនេះបានធ្វើឡើង បន្ទាប់ពីមានការផ្អាកជាបណ្តោះអាសន្ន នៅខែ ឧសភា ឆ្នាំ ២០១២ នូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និង ការពិនិត្យឡើងវិញនូវសម្បទានដែលបានផ្តល់រួច (បទបញ្ជា លេខ ០០១) ដែលលទ្ធផលពេញលេញរបស់បទបញ្ជានេះមិនទាន់ផ្សព្វផ្សាយជាសាធារណៈនៅឡើយទេ។ ការអនុវត្តកម្មវិធីជាតិផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី មានអាទិភាពជាងកម្មវិធីអាទិភាពផ្សេងទៀត ដោយសារមន្ត្រីសុរិយោដី និង ក្រុមយុវជន ត្រូវបានដាក់ពង្រាយនៅទូទាំងប្រទេស ដើម្បីវាស់វែងដីតាមជនបទ និង ចេញប័ណ្ណកម្មសិទ្ធិដីធ្លីដល់បុគ្គលឯកជន។ យុទ្ធនាការនេះទទួលបានជោគជ័យក្នុងពង្រឹងការធានាសិទ្ធិកាន់កាប់ដល់ប្រជាជនកម្ពុជាជាច្រើន។ យោងតាមទូរលេខរបស់រដ្ឋាភិបាល ចាប់ពីថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៣ មានប័ណ្ណកម្មសិទ្ធិចំនួន ២២៦. ២៥២ ប័ណ្ណ បានចែកជូនពលរដ្ឋរួចហើយ។ យុទ្ធនាការនេះក៏មានគោលបំណងផងដែរក្នុងកាត់បន្ថយទំនាស់ដីធ្លីនៅក្នុងតំបន់ជនបទ។ ប៉ុន្តែ ដោយសារជាគំនិតផ្តួចផ្តើមរយៈពេលខ្លី យុទ្ធនាការនេះពុំបានដោះស្រាយដីមានទំនាស់ទាំងមូលនៅក្នុងតំបន់ជនបទទូទាំងប្រទេសនៅឡើយ ហើយទំនាស់ដែលកំពុងកើតមានមួយចំនួននោះ នៅតែមិនទាន់បានដោះស្រាយ ខណៈពេលដែលទំនាស់ផ្សេងទៀតដែលកំពុងស្ងប់ស្ងៀម បានកើតឡើងម្តងទៀត។ មានភាពមិនប្រក្រតីមួយចំនួននៅក្នុងដំណើរការនោះ ត្រូវបានរាយការណ៍មកការិយាល័យ OHCHR ដោយសារខ្វះនូវភាពច្បាស់លាស់ ថាតើហេតុអ្វីបានដីមួយចំនួនត្រូវបានវាស់វែង ហើយដីនៅតំបន់ផ្សេងត្រូវបានដកចេញមិនវាស់វែង។

១១.	នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ការិយាល័យ OHCHR បានពិនិត្យឃើញថា មានទំនាស់ដីធ្លី ៧៤ ករណីដែលកំពុងតែកើតមានឡើង ហើយមិនទាន់ដោះស្រាយ រវាងសហគមន៍រងគ្រោះ អាជ្ញាធរ និង ក្រុមហ៊ុន ទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង ដែលជាការកើនឡើងបន្តិចបន្តួចចាប់តាំងពីឆ្នាំមុន។ ក្នុងចំណោមទំនាស់ទាំងនេះ មាន ៣២ ករណី (ក្នុងនោះមាន ៤ ករណីជាករណីថ្មី) ទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច និង សម្បទានដីផ្សេងទៀត (ក្នុងនោះមាន ១២ ករណី ទាក់ទងនឹងដីកាន់កាប់ដោយជនជាតិភាគតិច និង ២០ ករណី រងប៉ះពាល់ដោយសារការអនុវត្តបទបញ្ជាលេខ ០០១ )។ មានទំនាស់ ៤២ ករណី (ក្នុងនោះមាន ៦ ករណីជាករណីថ្មី) ពាក់ព័ន្ធនឹងប្រតិបត្តិការដីធ្លីផ្សេងទៀត (ក្នុងនោះមាន ០២ ករណី ទាក់ទងនឹងដីកាន់កាប់ដោយជនជាតិភាគតិច និង ០៣ ករណី រងប៉ះពាល់ដោយសារការអនុវត្តបទបញ្ជាលេខ ០០១)។ សកម្មភាពរបស់ការិយាល័យ OHCHR នៅក្នុងវិស័យនេះ យកទម្រង់នៃការសម្របសម្រួលតាមរយៈការពិភាក្សា ការត្រួតពិនិត្យដោយតុលាការ ព្រមទាំងការផ្តល់យោបល់ផ្នែកច្បាប់ និង នីតិវិធី។

១២.	ជាថ្មីម្តងទៀត ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ឃើញមានការប្រឈមមុខ (ជួនកាល មានអំពើហិង្សា) រវាងបុគ្គល សហគមន៍ សកម្មជនសិទ្ធិមនុស្ស និង អាជ្ញាធរ នគរបាល និង យោធា។ ការិយាល័យ OHCHR បានត្រួតពិនិត្យ និង និង អន្តរាគមន៍ជាច្រើនលើកច្រើនសារនៅក្នុងបាតុកម្ម និង ការតវ៉ា ដើម្បីទប់ស្កាត់អំពើហិង្សា ស្វែងរកលទ្ធផលតាមការចរចា និង ធានាឲ្យមានការដោះលែងជនដែលត្រូវបានឃុំខ្លួនដោយបំពាន។ ការិយាល័យ OHCHR បានមើលឃើញនូវឧប្បត្តិហេតុមួយចំនួនដែលមានការប្រើប្រាស់កម្លាំងហួសហេតុរបស់អាជ្ញាធរ។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ឃើញមានការផ្តើមប្រើប្រាស់ខែលប្រឆាំងនឹងកុបកម្មរបស់អាជ្ញាធរ។ ការិយាល័យ OHCHR បានបន្តត្រួតពិនិត្យរឿងក្តីរបស់បុគ្គលដែលនៅក្នុងអតីតកាល ត្រូវបានគេសួរយកចម្លើយ ចោទប្រកាន់ ឬ ដាក់ឲ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ ដោយសារពួកគេមានការពាក់ព័ន្ធក្នុងរឿងទំនាស់ដីធ្លី ប៉ុន្តែរឿងក្តីរបស់គេមិនដែលត្រូវបានបិទដោយតុលាការនោះទេ ហើយពួកគេនៅតែស្ថិតក្នុងស្ថានភាពការគម្រាមកំហែងពីការយាយី និង បំភិតបំភ័យ

(ការិយាល័យរក្សាបញ្ជីរឿងក្តីរបស់បុគ្គលចំនួន ១៧៧ រឿងក្តី ដែលមិនទាន់បានដោះស្រាយ ដែលក្នុងនោះ មានរឿងក្តីចំនួន៦ ជារឿងក្តីថ្មី ចាប់តាំងពីខែ មិថុនា ឆ្នាំ ២០១២)។

១៣. ការយកចិត្តទុកដាក់លើការងារជាក់លាក់របស់ការិយាល័យ OHCHR គឺលើកកម្ពស់ការធានាដល់សិទ្ធិកាន់កាប់ និងទប់ស្កាត់ការបណ្តេញចេញ និង ការតាំងលំនៅថ្មី រួមទាំងការលើកកម្ពស់ឲ្យមានដំណើរការផ្តល់ប្រឹក្សាប្រកបដោយសមធម៌ធានាឲ្យមានការផ្តល់សំណងសមស្រប ហើយករណីចាំបាច់ ធ្វើឲ្យប្រសើរឡើងនូវផែនការរើទីលំនៅទៅកន្លែងផ្សេង។ ក្រៅពីការត្រួតពិនិត្យ និង តាមដានរឿងក្តីលំនៅឋានក្នុងទីក្រុងជាច្រើន ការិយាល័យ OHCHR បានផ្តល់ការគាំទ្រសំខាន់ៗផ្នែកហិញ្ញវត្ថុដល់ការិយាល័យក្រុមមេធាវីការពារប្រយោជន៍សាធារណៈ ដែលបានផ្តល់ជំនួយផ្នែកច្បាប់ដល់សហគមន៍បីនៅក្រុងបាត់ដំបងដើម្បីដាក់ពាក្យសុំឲ្យមានការធានាដល់សិទ្ធិកាន់កាប់ ក្រោមគម្រោងសាកល្បង (ទាក់ទងនឹងសារាចរលេខ ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន)។

១៤. ទោះបីមានការកែលំអមួយចំនួននៅកន្លែងខ្លះពីអាជ្ញាធរមូលដ្ឋាន ម្ចាស់ជំនួយ និង អង្គការមនុស្សធម៌ក៏ដោយ ជារួមមក ស្ថានភាពនៅតែមិនល្អដដែលសម្រាប់សហគមន៍ដែលត្រូវបានការរុះរើទីលំនៅ ទោះបីការតាំងលំនៅឋានថ្មីរបស់គេទាក់ទងនឹងការបណ្តេញចេញថ្មីៗ ឬ កន្លែងតាំងលំនៅឋានថ្មីដែលបានបង្កើតយូរមកហើយ។ ការិយាល័យ OHCHR បានត្រួតពិនិត្យសិទ្ធិទទួលបានទឹកសុវត្ថិភាព និងអនាម័យនៅទីកន្លែងចំនួន ៩ ហើយតស៊ូមតិគាំទ្រធ្វើឲ្យមានប្រសើរឡើងនូវទម្លាប់អនាម័យ ដើម្បីរួមចំណែកកាត់បន្ថយជំងឺរីករាលដាល និង ធ្វើឲ្យមានប្រសើរឡើងនូវសុខភាព។ ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលក្នុងស្រុក ការិយាល័យ OHCHR បានផ្តល់នូវធុងចម្រោះទឹកដល់ ៤៥៩ គ្រួសារនៅក្នុងប្រាំមួយតំបន់ និង កំពុងគាំទ្រការសាងសង់បង្គន់អនាម័យដល់ ១១០ គ្រួសារ នៅកន្លែងតាំងលំនៅថ្មីនៅភ្នំបាត។

១៥. ការិយាល័យ OHCHR បានរួមចំណែកយ៉ាងច្រើនដល់ការស្រាវជ្រាវ និង ការតស៊ូមតិចំពោះការផ្តល់ និង ការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និង សម្បទានដីផ្សេងទៀត (រួមទាំងសម្បទានទាក់ទងនឹងកសិ-ឧស្សាហកម្ម ការជីកយករ៉ែ ទំនប់វារីអគ្គិសនី និង គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗផ្សេងទៀត) និង ផលប៉ះពាល់ដល់សិទ្ធិមនុស្សដោយសារសម្បទាន ជាពិសេសនៅក្នុងតំបន់ការពារ ដែលមានការទទួលស្គាល់។ ការិយាល័យ OHCHR បានរៀបចំឲ្យមានការប្រឹក្សាជាទៀងទាត់ជាមួយអង្គការ សង្គមស៊ីវិល និង អ្នកស្រាវជ្រាវ ហើយបានចូលរួមចំណែកក្នុងកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍លើកទឹកចិត្តចំពោះធ្វើឲ្យមានប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មាន និង ការប្រមូលទិន្នន័យ ដោយពុំមានទិន្នន័យផ្លូវការពេញលេញពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងចំណោមស្ថាប័នរដ្ឋាភិបាលផ្សេងទៀតឡើយ ហើយបានលើកទឹកចិត្តឲ្យមានសហប្រតិបត្តិការលើបញ្ហាតស៊ូមតិជុំវិញយុទ្ធនាការជាតិផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លី (ការអនុវត្តបទបញ្ជាលេខ ០០១) និង លើសម្បទានដី ជាទូទៅ។ ការិយាល័យ OHCHR បានគាំទ្រផ្នែកហិរញ្ញវត្ថុដល់ប្រភពទិន្នន័យចំហរបស់អង្គការក្រៅរដ្ឋាភិបាល ដែលមាននៅកន្លែងព័ត៌មានស្តីពីសម្បទានដីតាមខេត្ត និង ក្រុមហ៊ុន រួមទាំងការសង្ខេបស្តីពីបញ្ហាតាមផែនការ។ ដោយអនុលោមតាមអាណត្តិរបស់ខ្លួន ការិយាល័យ OHCHR បានគាំទ្រដល់ការងាររបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សស្តីពីសម្បទានដី និង កំពុងតាមដានអនុវត្តអនុសាសន៍របស់លោកចំពោះបញ្ហានេះ។

១៦. តាមការអញ្ជើញរបស់ក្រសួងបរិស្ថាន ការិយាល័យ OHCHR បានគាំទ្រដល់ដំណើរការប្រឹក្សាសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលដឹកនាំដោយក្រសួង និងបានផ្តល់យោបល់យ៉ាងច្រើនស្តីពីការធ្វើសុខដុមរម្មនីយកម្មនូវសេចក្តីព្រាងបច្ចុប្បន្នជាមួយបទដ្ឋានអន្តរជាតិអំពីតម្លាភាព ការចូលរួមពីសាធារណជន

និងសិទ្ធិទទួលបានព័ត៌មាន យេនឌ័រ ការទទួលខុសត្រូវរបស់សហគ្រាសធុរកិច្ច ការយល់ព្រមជាមុនដោយសេរី ការតាំងទីលំនៅថ្មី ព្រមទាំងយន្តការតវ៉ាដោយសារកើតទុក្ខមិនសុខចិត្ត និង ដំណើរការដោះស្រាយទំនាស់។

១៧. ទាក់ទងនឹងការលើកកម្ពស់សិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច ការិយាល័យ OHCHR ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងមហាផ្ទៃ។ ដោយមានកិច្ចសហការជាមួយអង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ការិយាល័យ OHCHR បានត្រួតពិនិត្យការខិតខំប្រឹងប្រែងនៅទូទាំងប្រទេស ដើម្បីឲ្យជនជាតិដើមភាគតិចរៀបចំ និងមានការទទួលស្គាល់ជានីតិបុគ្គល និងដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពសហគមន៍ ដូចដែលបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌច្បាប់ជាតិ។ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ គោលនយោបាយដែលកើតចេញពីការអនុវត្តបទបញ្ជាលេខ ០០១ ស្តីពីសម្បទានដី និង កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីឯកជនដែលបានចាត់ទុកជាអាទិភាពសម្រាប់ដីរុក្ខាប្រមាញ់ និង កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីរបស់ជនជាតិភាគតិចដែលពុំបានចាត់ទុកជាអាទិភាព ដែលបង្វែរធនធានពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ហើយជាឧបសគ្គរារាំងការរីកចម្រើននៃកម្មវិធី ផ្តល់ប័ណ្ណកម្មសិទ្ធិដីរបស់ជនជាតិភាគតិចដែលកំពុងដំណើរការ។ នៅក្នុងរឿងក្តីខ្លះ យុទ្ធនាការជាតិផ្តល់ប័ណ្ណកម្មសិទ្ធិដីឯកជនបានបណ្តាលឲ្យអាជ្ញាធរថ្នាក់ខេត្តធ្វើជាឧបសគ្គរារាំងដ៏មានប្រសិទ្ធភាពដល់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ពួកគេ។

១៨. ទោះបីមានឧបសគ្គទាំងនេះក៏ដោយ ការិយាល័យ OHCHR បានបន្តការគាំទ្រដល់ប្រាំពីរភូមិរបស់ប្រជាជនជនជាតិភ្នង នៅក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគីរី ផ្តល់ជំនួយថែមទៀតដល់សហគមន៍ស៊ុយនៅក្នុងប្រាំភូមិនៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ហើយបានពង្រីកការគាំទ្រដល់សហគមន៍ព័រ នៅស្រុកសំឡូត ខេត្តបាត់ដំបង។ ការិយាល័យ OHCHR ក៏បានរួមចំណែកដល់ការតស៊ូមតិទូទៅជាងនេះសម្រាប់សិទ្ធិផ្នែកភាសា សិទ្ធិវប្បធម៌ និង សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ដោយមានការប្រើប្រាស់ប្រព័ន្ធសារព័ត៌មាន (សេចក្តីថ្លែងការណ៍សារព័ត៌មាន ការបោះពុម្ពផ្សាយ និងវីដេអូ)។

១៩. ដើម្បីលើកកម្ពស់ឲ្យមានការទទួលខុសត្រូវថែមទៀតរបស់ការប្រកបធុរកិច្ចនៅក្នុងវិស័យដីធ្លី និង ដើម្បីឆ្លើយតបនឹងបទប្បញ្ញត្តិមិនគ្រប់គ្រាន់ និង ការត្រួតពិនិត្យលើធុរកិច្ចដែលកំពុងធ្វើសកម្មភាពនៅក្នុងប្រទេសកម្ពុជា (ដែលពាក់ព័ន្ធទៅនឹងសិទ្ធិពលកម្មផងដែរនោះ) ការិយាល័យ OHCHR បានរួមចំណែកដល់លើកកម្ពស់ការយល់ដឹង និង បង្កើតសមត្ថភាព នៅក្នុងវិស័យធុរកិច្ច និង សិទ្ធិមនុស្ស។ ការិយាល័យ OHCHR បានយកអង្គការសង្គមស៊ីវិល រដ្ឋាភិបាល តំណាងសហគមន៍ និង តួអង្គផ្នែកធុរកិច្ចជាគោលដៅ ដើម្បីគាំទ្រដល់ការកើនឡើងនៃការស្វែងយល់អំពីទស្សនៈនៅក្នុងគោលការណ៍ណែនាំស្តីពីធុរកិច្ច និង សិទ្ធិមនុស្ស ព្រមទាំងការអនុវត្តគោលការណ៍ទាំងនេះនៅក្នុងបរិបទកម្ពុជា។ ការិយាល័យ OHCHR បានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា និង កិច្ចពិគ្រោះយោបល់ចំនួន ៨ ដង ដល់សង្គមស៊ីវិលដែលមានអ្នកតំណាងរបស់អង្គការក្រៅរដ្ឋាភិបាល និង សហគមន៍ជនជាតិដើមភាគតិច ជាង ២០០ នាក់ នៅទូទាំងប្រទេស ហើយបានគាំទ្រឲ្យមានសមត្ថភាពប្រសើរជាងនេះ ដល់សង្គមស៊ីវិលស្តីពីសិទ្ធិទទួលបានយន្តការក្រៅប្រព័ន្ធតុលាការអំពីផលប៉ះពាល់ដល់សិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងធុរកិច្ច (នៅកម្រិតប្រតិបត្តិ កម្រិតជាតិ និង អន្តរជាតិ)។

២០. ការិយាល័យ OHCHR ក៏បានចែករំលែកនូវព័ត៌មានជាមួយបុគ្គលិករបស់អង្គភាពប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាល និង ម្ចាស់ជំនួយ ធុរកិច្ច និង សមាគមវិជ្ជាជីវៈអំពីធុរកិច្ច និង សិទ្ធិមនុស្ស បានគាំទ្រដល់កម្មវិធីវិទ្យុជាប្រចាំខែ ព្រមទាំងបានជួយរដ្ឋាភិបាលក្នុងការបង្កើតសៀវភៅរូបភាពស្តីពីបញ្ហាសហគមន៍ជនជាតិដើមភាគតិច។ ជាលទ្ធផលឃើញថាមានការកើនឡើងនូវការស្វែងយល់ក្នុងចំណោមសង្គមស៊ីវិលអំពីការទទួលខុសត្រូវរបស់រដ្ឋ និង តួអង្គធុរកិច្ចនៅក្នុងវិស័យដីធ្លី និង ការងារ ហើយបង្កើននូវចំណាប់អារម្មណ៍ និង សមត្ថភាពក្នុងការលើកកម្ពស់ការប្រកបធុរកិច្ចឲ្យ

មានការទទួលខុសត្រូវ ដូចដែលបានបញ្ជាក់ភស្តុតាងតាមជម្រើសរបស់សង្គមស៊ីវិលក្នុងស្រុកអំពីធុរកិច្ច និង សិទ្ធិមនុស្ស ដែលជាផែនការសម្រាប់ទិវាសិទ្ធិមនុស្ស ឆ្នាំ ២០១២។

**III- នីតិរដ្ឋ**

២១. កម្មវិធីនីតិរដ្ឋរបស់ការិយាល័យ OHCHR ប្រចាំកម្ពុជា មានគោលដៅគាំទ្រដំណើរការកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសនេះ ដោយយកចិត្តទុកដាក់លើការពង្រឹងនីតិរដ្ឋ។ កម្មវិធីនេះ ធ្វើការជាមួយតួអង្គទាំងឡាយដែលពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ភាគច្រើនជាមួយក្រសួងយុត្តិធម៌ ចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធតុលាការ មេធាវី និងនគរបាលយុត្តិធម៌។ កិច្ចសហប្រតិបត្តិការរវាងការិយាល័យ OHCHR និងរាជរដ្ឋាភិបាលមានលក្ខណៈរឹងមាំ។ ជាពិសេស កម្រិតនៃកិច្ចសហប្រតិបត្តិការជាមួយក្រសួងយុត្តិធម៌ ក្រោយមកជាមួយចៅក្រម និងព្រះរាជអាជ្ញា មានការកើនឡើងគួរឲ្យកត់សំគាល់នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ដែលនាំឲ្យមានការកើនឡើងនូវសកម្មភាពទាំងឡាយដែលបានសហការរៀបចំធ្វើជាមួយក្រសួងនេះ។

២២. កម្ពុជាបានផ្តល់សច្ចាប័នរួចហើយលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិមួយចំនួន។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ កម្ពុជាក៏បានក្លាយជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។ ការិយាល័យ OHCHR បានផ្តល់ការគាំទ្រនៅក្នុងដំណើរការផ្តល់សច្ចាប័ននេះ ជាអាទិ៍ តាមរយៈការផ្តល់ប្រឹក្សាយោបល់យ៉ាងច្រើនលើការតាក់តែងសេចក្តីថ្លែងហេតុសម្រាប់ដាក់ជូនសភាសុំការផ្តល់សច្ចាប័ន។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានស្នើសុំឲ្យការិយាល័យជួយធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរាជរដ្ឋាភិបាលអំពីអនុសញ្ញានេះ។

២៣. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានបន្តជួយដល់អ្នកពាក់ព័ន្ធក្នុងការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ អនុលោមតាមទម្លាប់អនុវត្ត និងបទដ្ឋានសិទ្ធិមនុស្ស។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ការិយាល័យ OHCHR បានសហការរៀបចំសន្និសីទថ្នាក់ជាតិមួយជាមួយក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តក្រមព្រហ្មទណ្ឌ ដែលមានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ និងមេធាវីមកពីគ្រប់បណ្តាខេត្ត។ កិច្ចពិភាក្សានេះ បានផ្តោតលើបទប្បញ្ញត្តិនៃក្រមនេះ អំពីផលប៉ះពាល់ដែលអាចមានលើសិទ្ធិក្នុងការបញ្ចេញមតិ (ឧទា. បទញុះញង់ បទបរិហារកេរ្តិ៍ ។ល។) និងបទប្បញ្ញត្តិទាក់ទងនឹងទោសជំនួស។ សន្និសីទនេះ គឺជាឱកាសដ៏សំខាន់មួយ ដើម្បីលើកកម្ពស់ការយល់ដឹងដល់សិក្ខាកាមពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ស្តីពីសិទ្ធិក្នុងការបញ្ចេញមតិ។ ដើម្បីសម្រេចគោលដៅនេះ ការិយាល័យ OHCHR បានបកប្រែជាភាសាខ្មែរនូវសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សលើមាត្រា ១៩ ស្តីពីសិទ្ធិក្នុងការបញ្ចេញមតិ ហើយបានបោះពុម្ពជាសៀវភៅតូចៗ។ នៅក្នុងសន្និសីទនេះ យើងបានអញ្ជើញសមាជិក ១ រូប នៃគណៈកម្មាធិការសិទ្ធិមនុស្ស ចូលរួមដើម្បីពិភាក្សាជាមួយសិក្ខាកាមអំពីសេចក្តីពន្យល់ទូទៅនេះ។

២៤. នៅពេលជាមួយគ្នានេះដែរ ការិយាល័យ OHCHR បានបន្តធ្វើការងារលើការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ និងជួបប្រជុំជាទៀងទាត់ជាមួយប្រធានតុលាការ និងព្រះរាជអាជ្ញានៅតាមបណ្តាខេត្ត ដើម្បីពិភាក្សាអំពីបញ្ហាប្រឈម ដែលពួកគេជួបប្រទះក្នុងការអនុវត្តក្រមនេះ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌។ ដើម្បីអនុវត្តបន្តពីសន្និសីទស្តីពីការអនុវត្តក្រមនេះ ដែលបានសហការរៀបចំក្នុងខែមិថុនា ឆ្នាំ២០១២ ការិយាល័យ OHCHR បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធ ជាមួយក្រសួងយុត្តិធម៌ ដើម្បីកែសម្រួលរូបមន្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលពាក់ព័ន្ធ ដើម្បីធានាថា ចៅក្រមចេញសេចក្តីសម្រេចដែលមានសំអាងហេតុ នៅពេលបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន។ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមចៅក្រម ត្រូវបានរៀបចំឡើង ក្នុងខែឧសភា ឆ្នាំ២០១៣ ដើម្បីពិនិត្យឡើងវិញនូវរូបមន្តដីកាទាំងនេះ មុនពេលដាក់ជូនទៅក្រសួងយុត្តិធម៌ជាចុងក្រោយ។

២៥. ដោយសារមានការសហការរៀបចំប្រកបដោយជោគជ័យ នូវកិច្ចប្រជុំតុមូលផ្នែកតុលាការចំនួន ៥ លើកក្នុងឆ្នាំ ២០១២ កន្លងមក ទើបក្រសួងយុត្តិធម៌បានយល់ព្រមបន្តកម្មវិធីនេះសម្រាប់ឆ្នាំ២០១៣។ នេះជាកម្មវិធីរួមគ្នាមួយ ដែលបានរៀបចំឡើងនៅតាមបណ្តាខេត្ត ដើម្បីពិភាក្សាជាមួយចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវីនៅថ្នាក់មូលដ្ឋាន អំពីបញ្ហាប្រឈមនានាក្នុងការអនុវត្តក្រមនេះ ដោយយោងជាពិសេសទៅលើទម្លាប់អនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ នៅអំឡុងពេលធ្វើរបាយការណ៍នេះ បណ្តាកិច្ចប្រជុំតុមូលផ្នែកតុលាការបានបង្កលក្ខណៈដល់អ្នកអនុវត្តច្បាប់នៅ អ.វ.ត.ក ចែករំលែកបទពិសោធន៍របស់ពួកគេជាមួយសហការីមកពីតាមបណ្តាខេត្តចំនួន១៧ ក្នុងចំណោមខេត្តចំនួន ២៤។ កិច្ចពិភាក្សាបានផ្តោតលើការឃុំខ្លួនបណ្តោះអាសន្ន និងបច្ចេកទេសស៊ើបសួរ។ ការិយាល័យ OHCHR បានបន្តគាំទ្រផងដែរដល់កិច្ចប្រជុំនានាជាទៀងទាត់រវាងនគរបាល តុលាការ និងពន្ធនាគារនៅតាមបណ្តាខេត្តនានា ជាពិសេស ខេត្តនៅភាគពាយព្យ តាមរយៈការិយាល័យ OHCHR ថ្នាក់ភូមិភាគ ដែលមានការិយាល័យនៅខេត្តបាត់ដំបង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងពិភាក្សាលើបញ្ហាទាំងឡាយដែលទាក់ទងនឹងការអនុវត្តក្រមនេះ។ នៅអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានគាំទ្រដល់កិច្ចប្រជុំរវាងនគរបាល តុលាការ និងពន្ធនាគារ ចំនួន១២ លើក នៅទូទាំងប្រទេស រាប់ទាំងកិច្ចប្រជុំក្នុងខេត្តចំនួនបួន ដែលយន្តការសម្របសម្រួលបែបនេះមិនធ្លាប់មានពីមុនមក។

២៦. ព្រះរាជអាជ្ញាដើរតួនាទីស្នូលក្នុងការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដោយសារពួកគេចូលរួមនៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ។ ដើម្បីផ្តល់ឱកាសឲ្យព្រះរាជអាជ្ញា ពិភាក្សាអំពីរបៀបដែលពួកគេបំពេញតួនាទីរបស់ខ្លួនស្របតាមក្រមនេះ ហើយជាពិសេសជាងនេះទៀត អំពីរបៀបដែលពួកគេអាចលើកស្ទួយការគោរពសិទ្ធិមនុស្សឲ្យកាន់តែប្រសើរឡើងនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនោះ ការិយាល័យOHCHR បានធ្វើការចាប់ដៃគូលើកដំបូង ជាមួយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីសហការរៀបចំកិច្ចប្រជុំព្រះរាជអាជ្ញាថ្នាក់ជាតិមួយលើកដំបូង ក្នុងខែមីនា ឆ្នាំ ២០១៣ កន្លងមក ដែលមានព្រះរាជអាជ្ញាទូទាំងប្រទេសកម្ពុជាបានចូលរួម។ កិច្ចពិភាក្សាបានផ្តោតលើតួនាទីរបស់ព្រះរាជអាជ្ញាក្នុងដំណាក់កាលមុនជំនុំជម្រះ និងក្នុងដំណាក់កាលជំនុំជម្រះ ការត្រួតពិនិត្យមើលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌ និងការឃ្លាំមើលការឃុំខ្លួនលើសពេលកំណត់។ សិក្ខាកាមបានឯកភាពឲ្យមានការបោះពុម្ពផ្សាយអនុសាសន៍ជាច្រើនបន្តបន្ទាប់ដែលបានដាក់បញ្ចូលក្នុងរបាយការណ៍នៃកិច្ចប្រជុំនេះ។

២៧. បន្ទាប់ពីការិយាល័យ OHCHR បានជួយគណៈមេធាវី ក្នុងការបញ្ចប់អត្ថបទសម្រាប់សេចក្តីកែសម្រួលក្រមសីលធម៌វិជ្ជាជីវៈមេធាវី ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នៅខែកញ្ញា ឆ្នាំ ២០១២ ហើយត្រូវបានចែកជូនដល់មេធាវីគ្រប់រូប។ គួរឲ្យកត់សំគាល់ថា សេចក្តីកែសម្រួលក្រមសីលធម៌នេះចែងថា មេធាវីគ្រប់រូបមានបេសកកម្មការពារសិទ្ធិមនុស្ស។ តាមក្រមសីលធម៌ថ្មីនេះ មេធាវីមិនចាំបាច់ជូនដំណឹង ឬពិគ្រោះយោបល់ជាមួយប្រធានគណៈមេធាវីឡើយ មុនពេលពួកគេនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលករណីនេះតម្រូវឲ្យមានការជូនដំណឹង និងពិគ្រោះយោបល់តាមក្រមសីលធម៌វិជ្ជាជីវៈមេធាវីចាស់។ ការិយាល័យ OHCHR និងគណៈមេធាវីបានសហការរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាសាធារណៈនូវក្រមសីលធម៌វិជ្ជាជីវៈមេធាវីថ្មីនេះ នៅអំឡុងខែ មេសា ឆ្នាំ ២០១៣។

២៨. នៅក្នុងឆ្នាំ ២០១២ ការិយាល័យ OHCHR បានបង្កើតមុខតំណែងមន្ត្រីតស៊ូមតិផ្នែកច្បាប់ ដែលមានគោលបំណងពង្រឹងមុខជំនាញមេធាវី ក្នុងការប្រើប្រាស់បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅតាមតុលាការ និងដើម្បីបន្តសកម្មភាពបណ្តឹងជាយុទ្ធសាស្ត្រ។ នៅក្នុងខែកញ្ញា ឆ្នាំ២០១២ ការិយាល័យ OHCHR បានរៀបចំវគ្គបណ្តុះបណ្តាលលើកដំបូងជា មួយក្រុមមេធាវី ស្តីពីរបៀបប្រើប្រាស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងយុត្តិសាស្ត្រចំពោះមុខតុលាការ។

មន្ត្រីតស៊ូមតិផ្នែកច្បាប់បានធ្វើការដោយផ្ទាល់ជាមួយមេធាវីក្នុងរឿងក្តីចំនួនប្រាំពីរ ក្នុងគោលបំណងជួយពួកគេក្នុងការការពារក្តីដែលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស និង ក្នុងការលើកអំណះអំណាងផ្អែកលើសិទ្ធិមនុស្សនៅចំពោះមុខតុលាការ។ តាមរយៈការងារ នេះ ញាំងឲ្យចៅក្រមបានយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សជាច្រើន ហើយបានចាត់ការប្រកបដោយជោគជ័យខ្លះៗ។ ជាឧទាហរណ៍ មន្ត្រីតស៊ូមតិផ្នែកច្បាប់បានធ្វើការជាមួយមេធាវីមួយរូប លើករណីមួយទាក់ទងនឹងសិទ្ធិរបស់មនុស្សស្រីស្រលាញ់មនុស្សស្រី មនុស្សប្រុសស្រលាញ់មនុស្សប្រុស មនុស្សភេទទីបី និង មនុស្សប្តូរភេទ (LGBT)។ បុគ្គលសាមីក្នុងករណីនេះ ត្រូវបានសម្រេចឲ្យរួចខ្លួននៅសាលាឧទ្ធរណ៍ ហើយក៏ត្រូវបានដោះលែងពីពន្ធនាគារឲ្យមានសេរីភាពវិញ។ ក្នុងករណីមួយផ្សេងទៀតទាក់ទងនឹងអនីតិជនម្នាក់ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នក្នុងពន្ធនាគារមួយដែលសម្រាប់ដាក់តែនីតិជនប៉ុណ្ណោះ មន្ត្រីតស៊ូមតិផ្នែកច្បាប់បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមេធាវីដើម្បីលើកអំណះអំណាងផ្អែកលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយដើម្បីធានាឲ្យមានការដោះលែងអនីតិជននោះ។ ក្នុងករណីមួយទាក់ទងនឹងស្ត្រីមានផ្ទៃពោះម្នាក់ ការិយាល័យ OHCHR បានជួយមេធាវីជាស្ត្រី រហូតទទួលបានការដោះលែងកូនក្តីរបស់គាត់ឲ្យនៅក្រៅឃុំ។

២៩. ការិយាល័យ OHCHR បានឃ្លាំមើលរឿងក្តីចំនួន ២៣ ទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្ស នៅអំឡុងពេលធ្វើរបាយការណ៍នេះ។ នៅក្នុងរឿងក្តីទាំងអស់នេះ ការិយាល័យ OHCHR បានធ្វើការទំនាក់ទំនងជាមួយចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ស្តីពីភាពជឿនលឿននៃរឿងក្តីទាំងនេះ។ ក្នុងរឿងក្តីខ្លះ ការិយាល័យ OHCHR បានជួយជនរងគ្រោះក្នុងការរកមេធាវី និង/ឬ បានផ្តល់ជំនួយថវិកាដល់មេធាវី ដើម្បីធ្វើការស៊ើបអង្កេត និងប្រមូលភស្តុតាងបន្ថែមដើម្បីជាប្រយោជន៍ដល់កូនក្តីរបស់ពួកគេ។ តាមការឃ្លាំមើលការជំនុំជម្រះចំនួនប្រាំបួនរឿងក្តីជាបន្តបន្ទាប់ ក្នុងនោះការជំនុំជម្រះចំនួនប្រាំមួយរឿងក្តី បានទទួលលទ្ធផលជាវិជ្ជមានសម្រាប់ចុងចោទ (ការសម្រេចឲ្យរួចខ្លួន ឬ បន្ធូរបន្ថយទោស)។

៣០. ភាពជឿនលឿនក្នុងការបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិ (NPM) បានជាប់គាំងនៅអំឡុងពេលធ្វើរបាយការណ៍នេះ។ ថ្វីបើមានការប្រកាសពីរាជរដ្ឋាភិបាលថានឹងធ្វើសេចក្តីព្រាងច្បាប់មួយ ដើម្បីបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិក៏ដោយ ក៏មិនមានភាពជឿនលឿនត្រូវបានធ្វើឡើងនៅអំឡុងពេលធ្វើរបាយការណ៍នេះដែរ។ ទោះបីយ៉ាងណាក៏ដោយ ការិយាល័យ OHCHR បានបន្តធ្វើការជាមួយសមាជិករបស់គណៈកម្មាធិការអន្តរក្រសួង (ដែលបច្ចុប្បន្នគណៈកម្មាធិការនេះ ដើរតួជាយន្តការបង្ការទារុណកម្មថ្នាក់ជាតិ) និងធ្វើការជាមួយលេខាធិការដ្ឋានរបស់ខ្លួន ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការចុះធ្វើទស្សនកិច្ចត្រួតពិនិត្យ។ ជាឧទាហរណ៍ សមាជិករបស់លេខាធិការដ្ឋាននេះបានរួមដំណើរជាមួយបុគ្គលិកការិយាល័យ OHCHR នៅពេលចុះធ្វើទស្សនកិច្ចត្រួតពិនិត្យនៅមណ្ឌលសង្គមកិច្ចមួយ និងពន្ធនាគារខេត្តមួយ ដើម្បីស្វែងយល់អំពីរបៀបចុះធ្វើទស្សនកិច្ចត្រួតពិនិត្យបែបនេះ។ ដើម្បីកាត់បន្ថយការប្រព្រឹត្តមិនគប្បីមកលើខ្លួន នៅតាមអង្គភាពនគរបាល ការិយាល័យ OHCHR បានបើកវគ្គបណ្តុះបណ្តាលច្រើនថែមទៀតតាមបណ្តាខេត្តដល់មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថ ស្តីពីការបង្ការទប់ស្កាត់ ការស៊ើបអង្កេត និងការចោទប្រកាន់ទៅលើអំពើទារុណកម្ម និងការប្រព្រឹត្តមិនគប្បីមក ដោយមានកិច្ចសហការជាមួយព្រះរាជអាជ្ញា។ បច្ចុប្បន្ននេះ វិធានការពិនិត្យតាមដាន កំពុងត្រូវបានធ្វើឡើង តាមរយៈការចុះធ្វើទស្សនកិច្ចទៅកាន់អង្គភាពនគរបាលថ្នាក់ស្រុក ដើម្បីវាយតម្លៃទៅលើប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាលទាំងនេះ។

៣១. ការិយាល័យ OHCHR ធ្វើការជាមួយសាលាឧទ្ធរណ៍ ដើម្បីកាត់បន្ថយភាពកកស្ទះនៃបណ្តឹងឧទ្ធរណ៍ ដែលមិនទាន់បានសម្រេច ដូចដែលបានពិពណ៌នានៅក្នុងផ្នែកនៃរបាយការណ៍នេះស្តីពីកំណែទម្រង់ពន្ធនាគារ។ ដើម្បីគាំទ្រដល់កិច្ចដំណើរការនេះ ការិយាល័យ OHCHR បានធ្វើការជាមួយអង្គការជំនួយផ្នែកច្បាប់ចំនួនពីរ គឺអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) និងអង្គការស្ពានយុត្តិធម៌អន្តរជាតិប្រចាំប្រទេសកម្ពុជា (IBJ) ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ក្នុងរឿងក្តីជាអាទិភាពចំនួនជាង ៣០០ រឿងក្តីដែលកំពុងចាត់ការនៅសាលាឧទ្ធរណ៍។ តាមរយៈកិច្ចសហការនេះ រឿងក្តីជាច្រើនត្រូវ

បានបើកសវនាការ ហើយភាពកកស្ទះនៃសំណុំរឿងឧទ្ធរណ៍មួយផ្នែកត្រូវបានដោះស្រាយជ្រះស្រឡះ។ គំនិតផ្តួចផ្តើមគំនិតនេះ បានកសាងបន្ថែមលើសមត្ថភាពរូបវន្តដែលមានស្រាប់របស់តុលាការ ដែលជាលទ្ធផលកើតចេញពីគំនិតផ្តួចផ្តើមខាងដើមរបស់ការិយាល័យ OHCHR ក្នុងការសាងសង់បន្ទប់សវនាការថ្មី។

៣២. ក្រៅពីការដោះស្រាយភាពកកស្ទះនៃសំណុំរឿងបណ្តឹងឧទ្ធរណ៍ ការិយាល័យ OHCHR និងប្រធានសាលាឧទ្ធរណ៍បានធ្វើការសហការគ្នាផងដែរ ដើម្បីកែលំអកិច្ចសហប្រតិបត្តិការរវាងស្ថាប័នតុលាការ និងអាជ្ញាធរពន្ធនាគារ។ សិក្ខាសាលាមួយត្រូវបានសហការរៀបចំឡើងក្នុងខែកញ្ញា ឆ្នាំ២០១២ ដោយមានការចូលរួមពីប្រធានតុលាការ ព្រះរាជអាជ្ញា និង ប្រធានពន្ធនាគារទាំងអស់។ សិក្ខាកាមបានផ្តោតកិច្ចពិភាក្សារបស់ខ្លួនលើមធ្យោបាយជាក់ស្តែងនានាក្នុងការកែលំអកិច្ចសហប្រតិបត្តិការក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ អនុសាសន៍តបពីសិក្ខាកាម មានភាពវិជ្ជមានក្រៃលែង ជាពិសេសនៅឱកាសបានជួបជុំសហការី និងបានពិភាក្សាអំពីបញ្ហាប្រឈមនានា។ នៅពេលបញ្ចប់កិច្ចប្រជុំនេះ សិក្ខាកាមបានឯកភាពគ្នាលើអនុសាសន៍មួយចំនួន ដែលផ្នែកខ្លះនៃអនុសាសន៍ទាំងនេះត្រូវបានអនុវត្តរួចហើយ។ ជាឧទាហរណ៍ យោងតាមព័ត៌មានដែលទទួលបាន ស្ថាប័នតុលាការបានចែករំលែកសាលក្រម ឬ សាលដីកាកាន់តែច្រើនឡើងជាប្រព័ន្ធដល់ពន្ធនាគារតាមខេត្តជាច្រើន ដែលវានឹងកាត់បន្ថយហានិភ័យនៃការឃុំខ្លួនលើសពេលកំណត់។ ដើម្បីទទួលបានរូបភាពពិស្តារថែមទៀតអំពីការអនុវត្តសិទ្ធិទទួលបានសវនាការប្រកបដោយយុត្តិធម៌នៅតុលាការជាន់ខ្ពស់ ការិយាល័យ OHCHR កំពុងគាំទ្រដល់ការឃ្លាំមើលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាទៅលើសវនាការនៅសាលាឧទ្ធរណ៍ ។

៣៣. ភាពជឿនលឿនឆ្ពោះទៅរកការបញ្ចប់សំណុំរឿង ០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បន្តជួបបញ្ហាប្រឈមនានា។ តុលាការនេះត្រូវបានរារាំងដោយការលំបាកខាងហិរញ្ញវត្ថុធ្ងន់ធ្ងរ ដែលបណ្តាលឲ្យបុគ្គលិកមិនទាន់ទទួលបានប្រាក់បៀវត្សប្រចាំខែ ជាច្រើនខែ ហើយមានការធ្វើកូដកម្ម។ នៅក្នុងខែកញ្ញា ឆ្នាំ២០១២ ចុងចោទម្នាក់ (អៀង ធីរិទ្ធ) ត្រូវបានដោះលែងពីការឃុំខ្លួន បន្ទាប់ពីធ្វើរោគវិនិច្ឆ័យរកឃើញជំងឺភ្លេចភ្លាំង ហើយប្រកាសថា មិនមានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមសវនាការ។ នៅក្នុងខែមីនា ឆ្នាំ២០១៣ សហចុងចោទ អៀង សារី ត្រូវជាប្តីរបស់អៀង ធីរិទ្ធ បានទទួលមរណភាព។ នៅពេលជាមួយគ្នានោះ “ការជំនុំជម្រះជាផ្នែកតូច” លើកដំបូងក្នុងសំណុំរឿង ០០២ ដោយផ្តោតលើការជម្លៀសប្រជាពលរដ្ឋដោយបង្ខំ កំពុងតែប្រព្រឹត្តទៅ ហើយសវនាការទាំងនេះរំពឹងថានឹងត្រូវបញ្ចប់នៅបំណាច់ ឆ្នាំ២០១៣ ខាងមុខនេះ។ ស្ថានភាពទាក់ទងនឹងសំណុំរឿង០០៣ និងសំណុំរឿង០០៤ នៅតែមានភាពមិនច្បាស់លាស់។

៣៤. ស្ថិតក្នុងបរិបទដ៏លំបាកនេះ ការិយាល័យ OHCHR បានបន្តការងាររបស់ខ្លួន ក្នុងការលើកស្ទួយកេរដំណែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ នៅអំឡុងពេលកំពុងធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានខិតខំប្រឹងប្រែងលើកយកការអនុវត្តរបស់អ.វ.ត.ក សម្រាប់សកម្មភាពនីតិរដ្ឋទាំងអស់របស់ខ្លួន។ ដូចដែលបានលើកឡើងខាងលើ ការិយាល័យ OHCHR និងក្រសួងយុត្តិធម៌ បានសហការរៀបចំកិច្ចប្រជុំតុមូលផ្នែកតុលាការ ចំនួន ៦ លើកថែមទៀត ដែលបានផ្តល់នូវវេទិកាដ៏សំខាន់ដើម្បីចែករំលែកការអនុវត្តល្អៗនៅអ.វ.ត.កជាមួយអ្នកអនុវត្តច្បាប់ក្នុងប្រទេស។ ការិយាល័យ OHCHR បានបន្តអនុវត្តផងដែរនូវសកម្មភាពផ្តោតទៅលើកេរដំណែលជាក់លាក់។ ជាពិសេស ការិយាល័យ OHCHR បានសម្របសម្រួលការងាររៀបចំសេចក្តីព្រាងដំបូងនៃនីតិមគ្គុទ្ទេសក៍ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយដាក់បញ្ចូលយុត្តិសាស្ត្ររបស់ អ.វ.ត.ក។ សេចក្តីព្រាងនេះត្រូវបានបកប្រែពីភាសាអង់គ្លេសទៅជាភាសាខ្មែរ ហើយកិច្ចពិគ្រោះយោបល់នឹងត្រូវរៀបចំឲ្យមានឡើងជាមួយចៅក្រម ព្រះរាជអាជ្ញា និងមេធាវីមុនពេលបញ្ចប់អត្តបទនេះ។ ការិយាល័យ OHCHR បានរៀបចំក្លឹបស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ វគ្គទី ២ ជាវគ្គសិក្សារយៈពេល ៨ សប្តាហ៍សម្រាប់និស្សិតច្បាប់ ១ ក្រុម ចំនួន២៥ នាក់ ដែលត្រូវបានជ្រើសរើស។ នៅអំឡុងពេលវគ្គសិក្សានិស្សិតទាំងនេះបានរៀនសូត្រអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ របៀបអនុវត្តសិទ្ធិទាំងនេះនៅ អ.វ.ត.ក

ហើយបានស្តាប់បទបង្ហាញអំពីសិទ្ធិទាំងនេះពីវាគ្មិនផ្សេងៗ រាប់ទាំងបទបង្ហាញពី អ.វ.ត.ក ផងដែរ។ និស្សិតទាំងនេះ ក៏បានចុះធ្វើទស្សនកិច្ចសិក្សានៅ អ.វ.ត.ក ផងដែរ។ នៅអំឡុងពេលកំពុងធ្វើរបាយការណ៍នេះ ដោយមានកិច្ចសហការពីគណៈមេធាវី ការិយាល័យ OHCHR បានរៀបចំកិច្ចពិភាក្សាផ្នែកច្បាប់ជាលើកដំបូងផងដែរ រវាងមេធាវីធ្វើការនៅ អ.វ.ត.ក (មេធាវីផ្នែកការពារក្តី និង មេធាវីដើមបណ្តឹងរដ្ឋប្បវេណី) និងមេធាវីធ្វើការក្នុងប្រព័ន្ធយុត្តិធម៌ក្នុងប្រទេស។ នៅទីបញ្ចប់ ការិយាល័យ OHCHR បានបកប្រែទៅជាភាសាខ្មែរនូវលិខិតុបករណ៍នីតិរដ្ឋរបស់ខ្លួន ស្តីពីការបង្កើនឲ្យបានជាអតិបរមានូវកេរដំណែលរបស់សាលាក្តីកូនកាត់ទាំងឡាយ ហើយលិខិតុបករណ៍នេះ ត្រូវបានបោះពុម្ពផ្សព្វផ្សាយ។

**IV. គាំទ្រកំណែទម្រង់ពន្ធនាគារ**

៣៥. កម្មវិធីគាំទ្រកំណែទម្រង់ពន្ធនាគារនេះ មានគោលដៅគាំទ្រឲ្យមានការផ្លាស់ប្តូរការគ្រប់គ្រងពន្ធនាគារ និងការប្រព្រឹត្តលើជនជាប់ឃុំនៅកម្ពុជា ក្នុងគោលដៅលើកកម្ពស់ការគោរពសិទ្ធិមនុស្សរបស់ជនជាប់ឃុំដែលមានទំនាស់នឹងច្បាប់។ ដើម្បីសម្រេចគោលដៅនេះ កម្មវិធីនេះធ្វើការយ៉ាងជិតស្និទ្ធជាមួយអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ (GDP) ព្រមទាំងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែទាំងអស់ ក្រោមសមត្ថកិច្ចរបស់ខ្លួន ក៏ដូចជា តួអង្គពាក់ព័ន្ធជាច្រើនទៀត ទាំងពីក្រសួងផ្សេងទៀត (ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ក៏ដូចជា សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានបន្តធ្វើការសហការជាមួយដៃគូទាំងអស់ និងគាំទ្រដល់កិច្ចសហប្រតិបត្តិការរវាងអគ្គនាយកដ្ឋានពន្ធនាគារ (GDP) និងអង្គការមិនមែនរដ្ឋាភិបាលនានា ហើយការរីកចម្រើនដ៏សំខាន់មួយចំនួនក្នុងការទទួលបានសិទ្ធិរបស់ជនជាប់ឃុំ ត្រូវបានកត់ត្រាទុក។

៣៦. ការបណ្តុះបណ្តាលបុគ្គលិកពន្ធនាគារគឺជាសកម្មភាពដ៏សំខាន់មួយ ដើម្បីពង្រឹងការគោរពសិទ្ធិរបស់ជនជាប់ឃុំ។ ការិយាល័យ OHCHR បានបន្តការគាំទ្ររបស់ខ្លួនដល់ការបង្កើតកម្មវិធីសិក្សា ក៏ដូចជា ការកសាងសមត្ថភាពរបស់គ្រូបង្គោលមកពីអគ្គនាយកដ្ឋានពន្ធនាគារ (GDP) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីអនុរក្សពន្ធនាគារនៃបណ្ឌិតសភានគរបាលកម្ពុជា(PAC)។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលផ្តោតលើជំនាញ និងវិធីសាស្ត្រ ដែលបានរៀបចំធ្វើជាមួយអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ គឺអង្គការ VBNK ចាប់តាំងពីខែមិថុនា ឆ្នាំ២០១១ បានបញ្ចប់ចុងក្រោយនៃវគ្គបណ្តុះបណ្តាល នៅក្នុងខែកក្កដា ឆ្នាំ២០១២ និង កិច្ចប្រជុំបូកសរុបលទ្ធផលជាចុងក្រោយជាមួយអាជ្ញាធរពន្ធនាគារនៅក្នុងខែកញ្ញា ឆ្នាំ២០១២។ ការវាយតម្លៃចុងក្រោយដោយសិក្ខាកាមអំពីការបណ្តុះបណ្តាជំនាញ ដែលបានទទួល ឬបានពង្រឹង គឺមានលក្ខណៈវិជ្ជមាន។ មេរៀនជាច្រើន ដែលក្នុងចំណោមនោះ មានសុខភាពផ្លូវចិត្តក្នុងពន្ធនាគារ ការទំនាក់ទំនងជាមួយជនជាប់ឃុំ និងការបង្ការជម្លោះក្នុងពន្ធនាគារ ក៏ត្រូវបានបង្កើតផងដែរ ក្នុងអំឡុងពេលធ្វើរបាយរាយការណ៍នេះ ជាមួយនឹងអង្គការចិត្តសង្គម អន្តរវប្បធម៌នៅកម្ពុជា (NGO TPO-Cambodia) និងស្របគ្នានេះដែរ សិក្ខាសាលាចំនួនបីសម្រាប់បណ្តុះបណ្តាលគ្រូបង្គោល និង បណ្តុះបណ្តាលបំប៉នបន្ថែម ត្រូវបានធ្វើឡើងនៅចន្លោះខែកក្កដា ឆ្នាំ២០១២ និងខែមីនា ឆ្នាំ២០១៣ ហើយបន្ទាប់មក មានការបណ្តុះបណ្តាលសាកល្បងសម្រាប់បុគ្គលិកពីមណ្ឌលអប់រំកែប្រែទី១ និងទី២ នៅជិតរាជធានីភ្នំពេញ។ សហប្រតិបត្តិការ បានបន្តជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) នៅកម្ពុជា បាននាំឲ្យមានការបង្កើតឲ្យមានការព្រាងកម្មវិធីសិក្សាស្តីពីសុខភាពទូទៅសម្រាប់បុគ្គលិកពន្ធនាគារដែលមិនមែនជាគ្រូពេទ្យ ដែលបច្ចុប្បន្ននេះ ត្រូវបានដាក់ជូនក្រសួងសុខាភិបាល ដើម្បីពិនិត្យឡើងវិញ។ ការិយាល័យ OHCHR បានជួយសម្រួលដល់ការរៀបចំផងដែរ នូវកិច្ចប្រជុំប្រចាំឆ្នាំលើកទីមួយនៃក្រុមបណ្តុះបណ្តាលរួមគ្នាមកពីអគ្គនាយកដ្ឋានពន្ធនាគារ(GDP) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីអនុរក្សពន្ធនាគារនៃបណ្ឌិតសភានគរបាលកម្ពុជា(PAC) ដែលបានផ្តោតលើការពង្រឹងកម្មវិធីសិក្សាក្នុងពន្ធនាគារ បន្តកសាងសមត្ថភាពរបស់គ្រូបង្គោល និងការរៀបចំផែនការសកម្មភាព។ កូនសៀវភៅអន្តរជាតិជាភាសាខ្មែរស្តីពី

អភិក្រមផ្តែកលើសិទ្ធិមនុស្សសម្រាប់ការគ្រប់គ្រងពន្ធនាគារ ដែលកន្លងមកត្រូវបានបកប្រែដោយការិយាល័យOHCHR ត្រូវបានបោះពុម្ពសម្រាប់ចែកចាយដល់បុគ្គលិកពន្ធនាគារនិងសិក្ខាកាមបុគ្គលិកពន្ធនាគារ។

៣៧. ការិយាល័យ OHCHR បន្តទទួលបានការអនុញ្ញាតឲ្យចូលពន្ធនាគារដោយសេរី នៅទូទាំងប្រទេសកម្ពុជា និងធ្វើសម្ភាសន៍ដោយសម្ងាត់ជនជាប់ឃុំ ដើម្បីឃ្លាំមើលស្ថានភាព និងការព្យាបាលជំងឺទូទៅ។ ក្រៅពីការតាមដានរឿងក្តីពាក្យសុំ ឬ បណ្តឹងនីមួយៗសម្រាប់គោលបំណងការពារ (ដូចជា ការភ្ជាប់ទំនាក់ទំនងរវាងបុគ្គលជាមួយអ្នកផ្តល់សេវាច្បាប់ និងវេជ្ជសាស្ត្រ) វិធីតាមឃ្លាំមើលនេះ បានបន្តផ្តោតលើទស្សនកិច្ចបង្ការ ដូចដែលបានពិនិត្យឃើញនៅក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT)។ ដូច្នេះ ទស្សនកិច្ចតាមឃ្លាំមើលបន្តបញ្ចូលដោយផ្ទាល់ទៅក្នុងការងារជាប្រព័ន្ធ ដែលអនុវត្តដោយការិយាល័យ OHCHR ដើម្បីពង្រឹងការងារគ្រប់គ្រងនិងការព្យាបាល។

៣៨. ការគោរពសិទ្ធិនីតិវិធីរបស់ជនជាប់ឃុំ នៅតែជាការផ្តោតមួយដ៏សំខាន់ នៅក្នុងអំឡុងពេលការធ្វើរបាយការណ៍នេះ ជាពិសេស សិទ្ធិរបស់ជនជាប់ឃុំរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍។ បើគ្មានសាលក្រម ឬ សាលដីកាស្ថាពរពីតុលាការទេ ជនជាប់ឃុំមិនអាចដាក់ពាក្យសុំបន្ធូរបន្ថយទោស និងលើកលែងទោសបានឡើយ ហើយការរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍មានរយៈពេលវែងនេះ បានដកហូតនូវសិទ្ធិនោះពីជនជាប់ឃុំរាប់រយនាក់។ កង្វះការយល់ដឹងរបស់អាជ្ញាធរពន្ធនាគារអំពីក្របខ័ណ្ឌច្បាប់ ដែលគ្រប់គ្រងជនជាប់ឃុំរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍ បាននាំឲ្យមានផងដែរនូវការឃុំខ្លួនលើសពេលកំណត់ ដូចជា នៅកម្ពុជា ច្បាប់ចែងថា ជនជាប់ឃុំរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍ នៅតែស្ថិតក្នុងការឃុំខ្លួនរហូតដល់សាលាឧទ្ធរណ៍បានសម្រេចលើរឿងក្តីរបស់ពួកគេ ដែលការឃុំខ្លួនអាចមានរយៈវែងជាងទោសជាប់ពន្ធនាគារដែលសាលាដំបូងបានសម្រេច។ ដោយសារតែខ្វះការយល់ដឹង ពន្ធនាគារបានអនុវត្តប្រព័ន្ធដូចគ្នា ទៅនឹងជនជាប់ឃុំដែលរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍របស់ខ្លួនផ្ទាល់។

៣៩. ដើម្បីជួយសម្រួលដល់ការជម្រះចេញនូវបណ្តឹងឧទ្ធរណ៍ចាស់ៗ ការិយាល័យ OHCHR បានរៀបចំបញ្ជីរឿងក្តីជាអាទិភាពដែលបានកំណត់យកពីការធ្វើជំរឿនឆ្នាំ២០១១ ស្តីពីជនជាប់ឃុំរង់ចាំសវនាការនៅសាលាឧទ្ធរណ៍។ បញ្ជីទាំងនេះត្រូវបានចែករំលែក និងបានទទួលយកដោយអាជ្ញាធរសាលាឧទ្ធរណ៍ ដែលចុងក្រោយបាននាំឲ្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ឃុំជាច្រើនត្រូវបានជំនុំជម្រះ និងចេញសាលដីកាស្ថាពរ។ គួរឱ្យកត់សម្គាល់ថា អាជ្ញាធរពន្ធនាគារបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការដឹកជញ្ជូនជនជាប់ឃុំបន្ថែមទៀត ដើម្បីចូលរួមក្នុងសវនាការលើបណ្តឹងឧរទ្ធណ៍របស់ខ្លួន។ មិនមានជនជាប់ឃុំបន្ថែមទៀត រង់ចាំសវនាកាបណ្តឹងឧទ្ធរណ៍របស់ខ្លួនសម្រាប់ដប់ឆ្នាំ ឬច្រើនជាងនេះទេ។ ជនជាប់ឃុំជាច្រើនដែលត្រូវបានសម្រេចឲ្យរួចខ្លួននៅសាលាដំបូងនោះ ចុងក្រោយ ក៏ត្រូវបានដោះលែងផងដែរបន្ទាប់ពីត្រូវបានសម្រេចឲ្យរួចខ្លួនម្តងទៀតនៅសាលាឧទ្ធរណ៍។

៤០. ព័ត៌មានត្រូវបានបញ្ចូលផងដែរទៅក្នុងសិក្ខាសាលាថ្នាក់ជាតិលើកដំបូង ដែលបានអញ្ជើញប្រធានពន្ធនាគារទាំងអស់មកជួបគ្នាជាមួយអាជ្ញាធរតុលាការ និងអាជ្ញាធរអយ្យការ (សូមមើលខាងលើ ត្រង់ផ្នែកនីតិរដ្ឋ)។ ការនេះបានជួយបង្កើនការយល់ដឹងដល់អាជ្ញាធរពន្ធនាគារអំពីល័ក្ខខ័ណ្ឌសម្រាប់ស្នើសុំឲ្យដោះលែងជនជាប់ឃុំដែលបានបណ្តឹងឧទ្ធរណ៍នៅពេលដែលពួកគេបានទទួលទោសពេញលេញរបស់សាលាដំបូង។ ជាលទ្ធផល ជនជាប់ឃុំជាច្រើនត្រូវបានដោះលែងតាមកាលកំណត់ ដែលនេះជាការរួមចំណែកកាត់បន្ថយករណីឃុំខ្លួនហួសពេលកំណត់ ដែលរង់ចាំសវនាការនៅសាលាឧទ្ធរណ៍។ កិច្ចខិតខំប្រឹងប្រែងរួមគ្នា កំពុងបន្តត្រូវការឲ្យមានតទៅទៀត រហូតដល់បណ្តឹងកកស្ទះនៅសាលាឧទ្ធរណ៍ត្រូវបានជម្រះអស់។

៤១. បន្ទាប់ពីការផ្តល់ជំនួយសង្គ្រោះបន្ទាន់រយៈពេលពីរឆ្នាំជាប់ៗគ្នាដល់ពន្ធនាគារមួយចំនួន នៅអំឡុងពេលមានទឹកជំនន់ក្នុងឆ្នាំ២០១០ និងឆ្នាំ២០១១ នៅប្រទេសកម្ពុជា ការិយាល័យ OHCHR បានសហការជាមួយក្រសួងមហាផ្ទៃ

រៀបចំសិក្ខាសាលាថ្នាក់ជាតិមួយស្តីពីការត្រៀមបង្ការគ្រោះមហន្តរាយក្នុងពន្ធនាគារក្នុងខែកក្កដាឆ្នាំ២០១២។ សិក្ខាកាមចូលរួម មានប្រធានពន្ធនាគារ និងមណ្ឌលអប់រំកែប្រែទាំងអស់ ក៏ដូចជា អភិបាល ឬអភិបាលរងខេត្ត តំណាងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយជាតិ និងខេត្ត អង្គភាពពន្លត់អគ្គិភ័យ និងអង្គការសង្គមស៊ីវិលនានាពាក់ព័ន្ធនឹងការឆ្លើយតបនឹងគ្រោះមហន្តរាយនៅក្នុងសហគមន៍។ កិច្ចប្រជុំនេះបានពិភាក្សាអំពីបទពិសោធន៍ជាក់លាក់អំពីបញ្ហាប្រឈម និងតម្រូវការរបស់ពន្ធនាគារកម្ពុជា ហើយបានឯកភាពលើជំហានមួយចំនួន ក្នុងការធ្វើឱ្យប្រសើរឡើងដល់ការត្រៀមបង្ការ ដូចជា ការរៀបចំផែនការត្រៀមបង្ការ និងការរៀបចំបង្កើតក្រុមការត្រៀមបង្ការ ឬបញ្ចូលអាជ្ញាធរពន្ធនាគារក្នុងគណៈកម្មាធិការពាក់ព័ន្ធនានា សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ។ នៅខាងចុងនៃរយៈពេលធ្វើរបាយការណ៍នេះ អនុសាសន៍មួយចំនួនត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងពន្ធនាគារទាំងឡាយដែលប្រឈមខ្លាំងបំផុតនឹងហានិភ័យ ហើយ ការិយាល័យ OHCHR បានផ្តល់ជំនួយសម្ភារៈដល់ពន្ធនាគារជាច្រើន ដើម្បីជួយឲ្យពន្ធនាគារទាំងនោះអនុវត្តផែនការត្រៀមបង្ការរបស់ខ្លួន។

៤២. ការិយាល័យ OHCHR បានបន្តចងក្រង និងវិភាគស្ថិតិ និងព័ត៌មានស្តីពីស្ត្រីក្នុងពន្ធនាគារ និងស្ត្រីដែលមានកូននៅក្នុងពន្ធនាគារសម្រាប់ការតស៊ូមតិជាមួយពន្ធនាគារ តុលាការ ព្រះរាជអាជ្ញា និងមេធាវី ក៏ដូចជា អង្គភាពពាក់ព័ន្ធក្នុងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ ស្របគ្នានេះដែរ កម្មវិធីនេះកំពុងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាដៃគូពីរ គឺអង្គការលីកាដូ និងអង្គការ Il Nodo ដើម្បីជួយផ្តល់សេវាដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលមានកូននៅក្នុងពន្ធនាគារ និងលើកយកបញ្ហាគោលនយោបាយទៅពិភាក្សាគ្នាជាមួយអាជ្ញាធរ និងដៃគូនានា។ បញ្ហាមួយក្នុងចំណោមបញ្ហាទាំងនេះគឺជាអត្រាខ្ពស់នៃស្ត្រីនៅក្នុងពន្ធនាគារក្នុងប្រទេសកម្ពុជា គឺជាង ៨% នៃចំនួនជនជាប់ឃុំគឺស្ត្រី ដែលប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេស ៣០ លើគេ នៅទូទាំងពិភពលោក អំពីចំនួនភាគរយនៃជនជាប់ឃុំជាស្ត្រី។ ទន្ទឹមនឹងកំណើននៃចំនួនជនជាប់ឃុំជាស្ត្រី មានស្ថិរភាពនៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការកើនឡើងយ៉ាងឆាប់រហ័សនេះ បានដាក់សម្ពាធបន្ថែមទៀតទៅលើប្រព័ន្ធពន្ធនាគារ ក្នុងការផ្តល់កន្លែងស្នាក់នៅ និងគ្រប់គ្រងជនជាប់ឃុំជាស្ត្រី ស្របតាមបទដ្ឋានដែលបានតម្រូវ។ បញ្ហាបន្ថែមមួយទៀតគឺការខ្វះគោលការណ៍ណែនាំ និងប្រព័ន្ធដោះស្រាយជាមួយកុមារដែលបានឃុំខ្លួនជាមួយម្តាយរបស់ពួកគេ (ជួនកាលជាមួយឪពុករបស់ពួកគេ) ជាពិសេស នៅពេលដែលពួកគេ ដល់អាយុអតិបរមា ដែលអាយុលើសពីនោះ មិនអាចអនុញ្ញាតឱ្យស្នាក់នៅជាមួយឪពុកម្តាយរបស់ពួកគេ នៅក្នុងពន្ធនាគារឡើយនេះបើតាមច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១។

៤៣. ការិយាល័យ OHCHR បានបន្តផ្តល់ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈ ដល់ពន្ធនាគារ និង អាជ្ញាធរខេត្តនានា ដើម្បីធ្វើឱ្យប្រសើរឡើងនូវសម្ភារៈបរិក្ខារពន្ធនាគារនៅ ស្របតាមអនុសាសន៍ស្តីពីការឃ្លាំមើល និងប្រកាសដែលនឹងត្រូវបានអនុម័តស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការសាងសង់ពន្ធនាគារ (ច្បាប់បន្ទាប់បន្សំដែលតម្រូវដោយច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១)។ ភារកិច្ចដ៏សំខាន់មួយនៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ គឺការធ្វើបង្អួចនៅក្នុងអគារឃុំខ្លួនជាបណ្តោះអាសន្ននៃមណ្ឌលអប់រំកែប្រែលេខ១ ដែលជាមណ្ឌលធំជាងគេបំផុតនៅកម្ពុជា ដែលនាំឱ្យមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់អំពីខ្យល់ចេញចូល និងកំដៅនៅក្នុងបន្ទប់ឃុំឃាំងនានា ហើយដែលពេលបច្ចុប្បន្ននេះ អាចឲ្យជនជាប់ឃុំមើលឃើញខាងក្រៅ។ បន្ទាប់ពីមានការតស៊ូមតិជាបន្តសម្រាប់បន្ទប់សុវត្ថិភាពសម្រាប់ជនជាប់ឃុំ នៅមន្ទីរពេទ្យបង្អែក និងដោយមានការឯកភាពពីអាជ្ញាធរពាក់ព័ន្ធ (ពន្ធនាគារ មន្ទីរសុខាភិបាលខេត្ត ព្រះរាជអាជ្ញាខេត្ត) មន្ទីរពេទ្យធំមួយត្រូវបានបំពាក់គ្រឿងឧបករណ៍ផ្សេងៗ (បន្ទាយមានជ័យ) និងខេត្តពីរផ្សេងទៀត បានចាប់ផ្តើមបំពាក់ (ខេត្តកំពង់ឆ្នាំង និងកោះកុង)។ ការិយាល័យ OHCHR បានជួយធ្វើឱ្យប្រសើរឡើងផងដែរនូវល័ក្ខខ័ណ្ឌក្នុងពន្ធនាគារបណ្តោះអាសន្នក្រោមស្តង់ដាចំនួនពីរ (ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ តាមរយៈការបើកបង្អួច និងការធ្វើឱ្យប្រសើរឡើងនូវផ្នែកអនាម័យក្នុងខេត្តរៀងៗខ្លួន) ទន្ទឹមនឹងបន្តជម្រុញឱ្យអាជ្ញាធររៀបចំបង្កើតឲ្យមានដំណោះស្រាយរយៈពេលវែង។

៤៤. សមិទ្ធលដទៃទៀតដែលសម្រេចបាន នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ រួមមាន ការធ្វើឲ្យប្រសើរឡើងដល់ខ្យល់ចេញចូល និងអនាម័យ នៅក្នុងពន្ធនាគារខេត្តព្រះសីហនុ ការធ្វើរបងហ៊ុមព័ទ្ធបរិវេណខាងក្នុង ដើម្បីផ្តល់លទ្ធភាពថែមទៀត ដល់ការទទួលបានខ្យល់បរិសុទ្ធ សកម្មភាពកសិកម្ម និងការជីកប្រឡាយទឹក ដើម្បីផ្គត់ផ្គង់ទឹកច្រើនថែមទៀតដល់ពន្ធនាគារខេត្តបន្ទាយមានជ័យ និងជួសជុលកែលម្អបង្គួចក្នុងពន្ធនាគារខេត្តក្រចេះ។ នាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកពន្ធនាគារ បានចូលរួមនៅក្នុងដំណើរនេះទាំងមូល ក៏ដូចជា អាជ្ញាធរពន្ធនាគារមូលដ្ឋាន ដើម្បីធានាភាពជាម្ចាស់ និងការកសាងសមត្ថភាព។

## V. សេរីភាពជាមូលដ្ឋាន និងសង្គមស៊ីវិល

៤៥. កម្មវិធីសង្គមស៊ីវិល និងសេរីភាពជាមូលដ្ឋាន មានគោលដៅពង្រឹងសមត្ថភាពបុគ្គល និងអង្គការនានា ក្នុងការអនុវត្តសេរីភាពជាមូលដ្ឋានរបស់ខ្លួន ក្នុងការបញ្ចេញមតិ យោបល់ សមាគម និងការជួបប្រជុំ។ កម្មវិធីនេះធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិល ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ស្ថានទូត និងគូអង្គអភិវឌ្ឍន៍ផ្សេងៗ ដើម្បីបង្កើត និងឃ្លាំមើលការអនុវត្តច្បាប់ និងគោលនយោបាយទាំងឡាយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រើប្រាស់សេរីភាពទាំងនេះ។ ការងារនេះ រាប់ទាំងការផ្តល់ការការពារដល់អ្នកការពារសិទ្ធិមនុស្ស ជនរងគ្រោះ ឬជនដែលអាចរងគ្រោះ តាមរយៈការឃ្លាំមើលករណីនីមួយៗ នៅពេលកើតមានឡើង និងធ្វើការតស៊ូមតិជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរខេត្តនានាដែលពាក់ព័ន្ធ ដើម្បីជួយគាំទ្រដល់ការគោរពសិទ្ធិរបស់ពួកគេ។ ការងារនេះផ្តោតផងដែរ លើការកសាងសមត្ថភាពដល់រដ្ឋាភិបាល និងសង្គមស៊ីវិល។ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យបានសង្កេតឃើញថា សហជីព និងសហគមន៍ជាច្រើន កាន់តែសកម្មឡើងក្នុងការតស៊ូមតិ ដើម្បីឲ្យមានការមានគោរពសិទ្ធិការងារ ដោយការធ្វើកូដកម្ម និងការដើរហែរក្បួនបាតុកម្ម។

៤៦. ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសង្គមស៊ីវិល ក្នុងការលើកស្ទួយការគោរពសិទ្ធិរបស់ពួកគេ វគ្គបណ្តុះបណ្តាសម្រាប់អ្នកការពារសិទ្ធិមនុស្ស បានបន្តជាផ្នែកដ៏សំខាន់មួយនៃការងាររបស់ការិយាល័យ OHCHR នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ ជាសរុប មានសកម្មជនសិទ្ធិមនុស្សច្រើនជាង ៥២៩ រូប បានទទួលអត្ថប្រយោជន៍ពីសកម្មភាពកសាងសមត្ថភាពនេះ ដែលអនុវត្តដោយកម្មវិធីនេះ ទាក់ទងនឹងការលើកកម្ពស់សេរីភាពជាមូលដ្ឋាន។ ការិយាល័យបានផ្តល់អាទិភាពដល់ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិជួបប្រជុំដោយសន្តិវិធី និងការបញ្ចេញទស្សនៈរបស់ពួកគេដោយសេរី នៅពេលដែលការិយាល័យ OHCHR បានកត់សម្គាល់ថា ទាំងតំណាងសហគមន៍ ទាំងអាជ្ញាធរមានការយល់ច្រឡំអំពីបទប្បញ្ញត្តិជាតិដែលពាក់ព័ន្ធ ជាពិសេស បទប្បញ្ញតិច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ ឧទាហរណ៍ ការិយាល័យ OHCHR បានសង្កេតឃើញថា មានករណីជាច្រើន អង្គការសង្គមស៊ីវិល និងសហគមន៍នានាបានយល់ឃើញថា ពួកគេមានកាតព្វកិច្ចត្រូវជូនដំណឹងទៅអាជ្ញាធរអំពីការប្រមូលផ្តុំដែលបានគ្រោងធ្វើ ដែលក្នុងករណីទាំងនោះ ច្បាប់មិនតម្រូវឲ្យមានការជូនដំណឹងឡើយ។ សហគមន៍ បានបង្ហាញថា ពួកគេពេញចិត្តក្នុងការជូនដំណឹងទៅអាជ្ញាធរ ទោះបីជាច្បាប់មិនបានតម្រូវក្តី ជាជាងមានការបង្អាក់រំខានទៅលើការប្រមូលផ្តុំរបស់ខ្លួន។ ដើម្បីធ្វើឲ្យស្ថានភាពល្អប្រសើរឡើង ការិយាល័យ OHCHR ដោយសហការជាមួយវិទ្យាស្ថានគ្រប់គ្រងបស្ចឹម-បូព៌ា(EWMI) បានធ្វើការបណ្តុះបណ្តាលដោយមានការចូលរួមពីអ្នកការពារសិទ្ធិមនុស្ស រួមទាំងសហគមន៍ដែលត្រូវបានបណ្តេញចេញ សមាគមព្រៃឈើ និងនេសាទ អង្គការមិនមែនរដ្ឋាភិបាល និងសហជីពកម្មករនានា ស្តីពីបទប្បញ្ញត្តិនៃច្បាប់ស្តីពីការធ្វើការបាតុកម្មដោយសន្តិវិធី និងគោលការណ៍ណែនាំជាផ្លូវការសម្រាប់អនុវត្តច្បាប់នេះ។ ដោយសហការជាមួយវិទ្យាស្ថានគ្រប់គ្រងបស្ចឹម-បូព៌ា(EWMI) ការិយាល័យ OHCHR បានផ្សព្វផ្សាយផងដែរនូវទម្រង់សម្រាប់ធ្វើរបាយការណ៍ដែលនឹងប្រើប្រាស់ដោយអង្គការសង្គមស៊ីវិល ដើម្បីឃ្លាំមើលជាលក្ខណៈប្រព័ន្ធ និងធ្វើរបាយការណ៍ឲ្យបានពេញលេញ និងតស៊ូមតិអំពីការរំលោភបំពានដែលទាក់ទងនឹងសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធីរបស់ពួកគេ ជាពិសេស ទាក់ទងនឹងការអនុវត្តច្បាប់ស្តី

ពីការធ្វើបាតុកម្មដោយសន្តិវិធី។ ការិយាល័យ OHCHR បានបន្តផ្តល់ផងដែរនូវកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមមន្ត្រីរាជការស៊ីវិល អំពីរបៀបអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីក្នុងលក្ខណៈមួយដែលស្របទៅនឹងកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា។

៤៧. លើសពីនេះទៀត កម្មវិធីសង្គមស៊ីវិល និងសេរីភាពជាមូលដ្ឋានរបស់ការិយាល័យ OHCHR បានពង្រឹងសមត្ថភាពអ្នកការពារសិទ្ធិមនុស្ស រួមទាំងសកម្មជនសហជីព ដើម្បីឃ្លាំមើលជាប្រព័ន្ធនិងគ្រប់គ្រាន់ រាយការណ៍និងធ្វើការតស៊ូមតិជាមួយអាជ្ញាធរ ឬតួអង្គពាក់ព័ន្ធដទៃទៀត អំពីស្ថានភាពនៃការរំលោភសិទ្ធិមនុស្ស។ វគ្គបណ្តុះបណ្តាលនេះមានសកម្មជន ១១៤ នាក់ មកពីបណ្តាខេត្តចំនួនដប់ បានចូលរួម។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ការិយាល័យ OHCHR បានរៀបចំសិក្ខាសាលាមួយស្តីពីការរឹតត្បិតដែលអាចអនុញ្ញាតទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយមានការគាំទ្រពីអ្នកជំនាញការនៃគណៈកម្មាធិការសិទ្ធិមនុស្ស។ កម្មវិធីនេះបានផ្តោតលើការពិភាក្សាគ្នាជាមួយសង្គមស៊ីវិលអំពីអញ្ញត្រកម្មដែលអាចអនុញ្ញាតទៅលើការគោរពសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា។

៤៨. ការិយាល័យ OHCHR បានសម្របសម្រួលជាទៀងទាត់ រវាងអាជ្ញាធរ និងសហគមន៍ ឬអង្គការសង្គមស៊ីវិល ដើម្បីធានាថា ការជួបប្រជុំដោយសន្តិវិធីអាចប្រព្រឹត្តទៅបាន ដោយស្របតាមបញ្ញត្តិច្បាប់សិទ្ធិមនុស្សជាតិ និងអន្តរជាតិ។ ដើម្បីបង្កើតវិធីសាស្ត្រមួយប្រកបដោយនិរន្តរភាព ចំពោះការប្រមូលផ្តុំដោយសន្តិវិធី ការិយាល័យ OHCHR បានរៀបចំឲ្យមានកិច្ចប្រជុំតុមូលជាបន្តបន្ទាប់នៅតាមបណ្តាខេត្ត ដែលមានមន្ត្រីខេត្ត និងតំណាងសង្គមស៊ីវិលមកពីខេត្តដែលមានបញ្ហា អាចជួបពិភាក្សាគ្នាអំពីកង្វល់របស់ខ្លួនទៅលើសេរីភាពក្នុងការជួបប្រជុំ និងព្រមព្រៀងគ្នាលើតួនាទីក្នុងគ្រប់គ្រងកម្មវិធីនៅថ្ងៃខាងមុខឲ្យស្របតាមច្បាប់។ ការនេះមានប្រសិទ្ធភាពយ៉ាងពិសេស នៅក្នុងអំឡុងពេលនៃទិវាសិទ្ធិមនុស្សឆ្នាំ២០១២ នៅពេលដែលការិយាល័យបានធ្វើអន្តរាគមន៍ ដើម្បីធានាឲ្យកម្មវិធីផ្សេងៗដែលសហគមន៍បានរៀបចំធ្វើបានប្រព្រឹត្តទៅដោយដោសន្តិវិធី។

៤៩. ប្រសិនជាការស្រមុះស្រមួលមុនមិនអាចធ្វើទៅបាន ការិយាល័យ OHCHR ឃ្លាំមើលបាតុកម្ម ការដើរហែក្បួន និងប្រភេទនៃការប្រមូលផ្តុំផ្សេងទៀត ដែលអាចមានហានិភ័យនៃអំពើហិង្សារវាងអ្នកតវ៉ា និងអាជ្ញាធរ។ នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានឃ្លាំមើលព្រឹត្តិការណ៍បែបនេះចំនួន ២២ នៅរាជធានីភ្នំពេញតែមួយគត់។ គោលបំណងនៃការធ្វើអន្តរាគមន៍របស់ការិយាល័យ OHCHR គឺដើម្បីកាត់បន្ថយហានិភ័យនៃអំពើហិង្សាទន្ទឹមនឹងព្យាយាមធានាថា សិទ្ធិសេរីភាពនៃការប្រជុំ និងការបញ្ចេញមតិ ត្រូវបានគោរព។ ការិយាល័យ OHCHR ធ្វើការជាមួយអាជ្ញាធរ និងអ្នកដឹកនាំការតវ៉ា ដើម្បីឲ្យមានការព្រមព្រៀងគ្នា (ប្រសិនជាអាចធ្វើបាន) ដើម្បីឱ្យការតវ៉ានោះប្រព្រឹត្តទៅបានដោយសន្តិវិធី។ ឧទាហរណ៍ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មានទាំងការតវ៉ានៅខាងក្រៅសាលាដំបូងរាជធានីភ្នំពេញអំឡុងពេលសវនាការករណីរបស់លោក ម៉ម សូណង់ដូ កាលពីខែកញ្ញា ឆ្នាំ២០១២ និងការប៉ុនប៉ងដោយសភាប្រជាជនមូលដ្ឋានរបស់អាស៊ាន ដើម្បីដាក់ញត្តិមួយទៅរដ្ឋសភាជាតិកម្ពុជា មុនពេលកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី៧ក្នុងខែវិច្ឆិកាឆ្នាំ២០១៣។

៥០. ករណីដែលការតវ៉ាក្លាយទៅជាអំពើហិង្សា ការិយាល័យ OHCHR បានព្យាយាមធ្វើឲ្យស្ថានភាពនោះស្ងប់ស្ងាត់។ ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងនេះបានទទួលជោគជ័យតិចតួច នៅអំឡុងពេលធ្វើរបាយការណ៍នេះ ការបង្ហាញវត្តមានរបស់ការិយាល័យ OHCHR ហាក់បីដូចជាបានជួយទប់ស្កាត់មិនឲ្យមានការកើនឡើងថែមទៀត។ នៅអំឡុងពេលធ្វើរបាយការណ៍នេះ ឃើញមានការបន្តប្រើប្រាស់កម្លាំងសន្តិសុខឯកជន ដើម្បីឆ្លើយតបនឹងការតវ៉ា ដែលក្នុងនោះមានករណីប្រើប្រាស់កម្លាំងហួសហេតុមួយចំនួន។ ការវិវឌ្ឍន៍ថ្មី គួរឲ្យព្រួយបារម្ភមួយ គឺការណែនាំឲ្យប្រើ និងការប្រើប្រាស់ខែលឆក់ប្រឆាំងកុប្បកម្ម ដោយនគរបាលទៅលើហ្វូងបាតុករ។ ការិយាល័យ OHCHR បានធ្វើអន្តរាគមន៍ផងដែរ ក្នុង

ករណីដែលមានការឃុំខ្លួនអ្នកតវ៉ា ជាពិសេស ទាក់ទងនឹងទំនាស់ដីធ្លី ការតវ៉ារបស់កម្មកររោងចក្រកាត់ដេរ និងសកម្មជនសហជីព។ ការិយាល័យ OHCHR បានព្យាយាមធ្វើការស្វែងរកការដោះលែង ប្រសិនជាមានការឃុំខ្លួនធ្វើឡើងដោយបំពានឬដើម្បីធានាសិទ្ធិមានមេធាវីនិងការថែទាំវេជ្ជសាស្ត្រប្រសិនជាចាំបាច់។

៥១. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មានព្រឹត្តការណ៍សាធារណៈធំៗមួយចំនួននៅកម្ពុជា ព្រឹត្តការណ៍ដែលគួរឲ្យកត់សំគាល់បំផុតនោះ គឺកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធដទៃទៀត ក្នុងខែវិច្ឆិកា ឆ្នាំ ២០១២ និងព្រះរាជពិធីបុណ្យព្រះបរមសពព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបិតាឯករាជ្យ នៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៣។ ការិយាល័យ OHCHR បានស្នើសុំធ្វើការជាមួយអាជ្ញាធរ ដើម្បីស្វែងរកដំណោះស្រាយទៅលើស្ថានភាពរបស់ក្រុមបុគ្គលចម្រុះដ៏ធំមួយ ដែលត្រូវបានចាប់ប្រមូលមកឃុំខ្លួន (ដោយគ្មានការត្រួតពិនិត្យពីតុលាការ) ពីតាមដងផ្លូវនានា ក្នុងរាជធានីភ្នំពេញនៅមុនពេលកិច្ចប្រជុំកំពូលនេះ។ ក្រុមនេះ រួមមាន ជនគ្មានផ្ទះសម្បែង ជនវិកលចរិក អ្នករកស៊ីផ្លូវភេទ កម្មកររោងចក្រ និងកម្មករសំណង់ ព្រមទាំងកុមារ។ នៅក្នុងអំឡុងពេលកិច្ចប្រជុំកំពូលកន្លងមក កិច្ចសហប្រតិបត្តិការស្រដៀងគ្នានេះ បាននាំឲ្យមានការដោះលែងបុគ្គលទាំងនេះ តាមការសមស្របឲ្យស្ថិតនៅក្នុងការថែ ទាំរបស់អង្គការមិនមែនរដ្ឋាភិបាលវិញ។ ការិយាល័យ OHCHR បានស្នើផ្តល់ជាជំនួយផ្នែកបច្ចេកទេសដល់សាលារាជធានីភ្នំពេញ ក្នុងការរៀបចំបង្កើតឲ្យមានដំណើរការមួយ ដើម្បីជៀសវាងករណីចាប់ឃុំខ្លួនដោយបំពានស្រដៀងគ្នានេះនៅថ្ងៃខាងមុខទៀត។

៥២. ដោយកសាងបន្ថែមលើការងារកន្លងមក ការិយាល័យ OHCHR និងអង្គការ UNICEF បានធ្វើការជាមួយរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្សនៅតាមមជ្ឈមណ្ឌលសង្គមកិច្ច មជ្ឈមណ្ឌលយុវនីតិសម្បទា និងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ អនុលោមតាមការសម្រេចមួយរបស់រដ្ឋាភិបាលនៅដើមឆ្នាំ២០១២ ការិយាល័យ OHCHR ស្វាគមន៍ការពិតដែលថា មជ្ឈមណ្ឌលសង្គមកិច្ចនៅព្រៃស្ពឺក្នុងរាជធានីភ្នំពេញ មិនត្រូវបានប្រើប្រាស់ទៀតទេសម្រាប់ការឃុំខ្លួនដោយបំពាន ដូចបានរាយការណ៍កន្លងមក។ ការិយាល័យ OHCHR និងអង្គការ UNICEF កំពុងធ្វើការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSAVY) ដើម្បីអនុវត្តអនុសាសន៍ចេញពីការសិក្សារួមគ្នាដោយឯករាជ្យ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១១ មានចំណងជើងថា " ការវាយតម្លៃអំពីគោលនយោបាយ នីតិវិធី និងការអនុវត្ត ក្នុងការបញ្ជូន ការដាក់ ការគ្រប់គ្រង ការស្តារនីតិសម្បទារ និង ការធ្វើសមាហរណកម្មកុមារ ស្ត្រី និងជនដែលងាយរងគ្រោះនៅតាមមជ្ឈមណ្ឌលសង្គមកិច្ច មជ្ឈមណ្ឌលយុវនីតិសម្បទា និងមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ក្រោមសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា(MOSAVY)"។

**VI. ទំនាក់ទំនងសាធារណៈ និងការងារតស៊ូមតិ**

៥៣. ការិយាល័យ OHCHR បានបន្តពង្រីកទំនាក់ទំនងសាធារណៈ និងការងារតស៊ូមតិរបស់ខ្លួន នៅទូទាំងប្រទេស ដើម្បីលើកស្ទួយសិទ្ធិមនុស្សឱ្យកាន់តែប្រសើរឡើងថែមទៀត និងដោះស្រាយបញ្ហាតាមវិស័យនីមួយៗ និងតម្រូវការរបស់អតិថិជន។ ដោយប្រើប្រាស់ឧបករណ៍ព័ត៌មានមួយចំនួន ការិយាល័យ OHCHR បានធ្វើការផ្សព្វផ្សាយទៅដល់វិស័យផ្សេងៗនៃសង្គម រួមទាំងស្ថាប័នសិក្សា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន មន្ត្រីរដ្ឋាភិបាល និងសហគមន៍នៅតាមបណ្តាខេត្តឆ្ងាយៗ។

៥៤. នៅក្នុងបរិបទនៃសេចក្តីប្រកាសឆ្នាំ២០១១ស្តីពីការអប់រំ និងការបណ្តុះបណ្តាលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ការិយាល័យ OHCHR បានប្រកាសបើកជាផ្លូវការនូវកម្មវិធីសិក្សាអំពីសិទ្ធិមនុស្សសម្រាប់សាកលវិទ្យាល័យនានានៅរាជធានីភ្នំពេញ ដែលផ្តល់បឋកថាខ្លីៗលើប្រធានបទសិទ្ធិមនុស្សជាក់លាក់មួយចំនួន។ រហូតមកដល់ពេលនេះ

ការិយាល័យ OHCHR បានធ្វើបទបង្ហាញចំនួនបីដល់និស្សិត និង សាស្ត្រចារ្យ ជាង ៥០០ នាក់ នៅសាកលវិទ្យាល័យចំនួនបី។ តបតាមការស្នើសុំរបស់សាកលវិទ្យាល័យមេគង្គកម្ពុជា ដែលជាសាកលវិទ្យាល័យតែមួយគត់នៅកម្ពុជា ដែលផ្តល់កម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតផ្នែកសិទ្ធិមនុស្ស បុគ្គលិកការិយាល័យ OHCHR បានផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលខ្លីៗចំនួនពីរលើក ស្តីពីប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

៥៥. តបតាមការអញ្ជើញ និងក្នុងភាពជាដៃគូជាមួយក្រសួងព័ត៌មាន ការិយាល័យ OHCHR បានបណ្តុះបណ្តាល អ្នកវិជ្ជាជីវៈសារព័ត៌មានចំនួន ៥០ នាក់ និងបុគ្គលិកក្រសួងនេះ ស្តីពីវិធីសាស្ត្រផ្នែកសិទ្ធិមនុស្សនៅក្នុងវិជ្ជាជីវៈសារព័ត៌មាន នៅក្នុងខែសីហា ឆ្នាំ២០១២។ ការបណ្តុះបណ្តាលរយៈពេលពីរថ្ងៃនេះ បានដាក់បញ្ចូលការផ្តោតសំខាន់អំពីគោលការណ៍សន្មតជាមុនថាគ្មានទោស នៅក្នុងរឿងព្រហ្មទណ្ឌ និងសិទ្ធិឯកជន។

៥៦. ការផ្សព្វផ្សាយឯកសារបោះពុម្ពផ្សាយ និងឯកសារព័ត៌មានដទៃទៀត ដោយការិយាល័យ OHCHR បានកើនឡើងជារៀងរាល់ឆ្នាំ សម្រាប់ឯកសារបោះពុម្ពផ្សាយថ្មីៗ ដែលបានបង្កើតឡើង និង បានចែកចាយមួយចំនួននៅទូទាំងប្រទេស។ ឯកសារបកប្រែជាភាសាខ្មែរថ្មីៗ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ រួមមានសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សស្តីពីសេរីភាពនៃគំនិត និងការសម្តែងមតិ ចំណែកឯឯកសារបោះពុម្ពផ្សាយថ្មី មានអត្ថបទបកស្រាយជារូបភាពនៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដែលផ្តោតសំខាន់លើសហគមន៍ជនជាតិដើមភាគតិច ដែលបានផលិតឡើង ដោយមានកិច្ចសហការជាមួយអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO)។ ជាសរុប ឯកសារបោះពុម្ពផ្សាយចំនួនជាង ៧៥.០០០ ច្បាប់ និង ឯកសារព័ត៌មាន ក្នុងទម្រង់ដទៃទៀតត្រូវបានផ្សព្វផ្សាយនៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ ការផ្សព្វផ្សាយនេះ រាប់បញ្ចូលទាំងការផ្តល់កម្រងឯកសារព័ត៌មានចំនួន ៤២៤ ឈុត ទៅដល់វិទ្យាល័យរដ្ឋទាំងអស់នៅទូទាំងប្រទេស ដើម្បីគាំទ្រដល់ការប្រកួតប្រជែងលើប្រធានបទសិទ្ធិមនុស្សដែលបានរៀបចំឡើងដោយរដ្ឋាភិបាល។

៥៧. ការិយាល័យ OHCHR បានបន្តផ្តល់បណ្ណាល័យតូចៗអំពីសិទ្ធិមនុស្សដល់សាកលវិទ្យាល័យនានា និងមជ្ឈមណ្ឌលគរុកោសល្យ និងវិក្រឹត្យការរបស់រដ្ឋនៅទូទាំងប្រទេស ក៏ដូចជាស្ថាប័នសំខាន់ៗរបស់រដ្ឋាភិបាល។ គិតត្រឹមចុងខែមិថុនាឆ្នាំ២០១៣ ការិយាល័យ OHCHR នឹងបានផ្តល់កម្រងឯកសារស្តីពីសិទ្ធិមនុស្សចំនួន ៧០ ឈុត ដល់ស្ថាប័នដែលត្រូវទទួលចំនួន៦០។

៥៨. ក្នុងចំណោមហិរញ្ញប្បទានដែលការិយាល័យ OHCHR បានផ្តល់នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ហិរញ្ញប្បទានចំនួនពីរ បានផ្តោតលើប្រព័ន្ធផ្សព្វផ្សាយ។ ហិរញ្ញប្បទានមួយ ត្រូវបានផ្តល់ឲ្យមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) បានគាំទ្រដល់ការបណ្តុះបណ្តាលតំណាងសហគមន៍ជនជាតិដើមភាគតិចស្តីពីការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការតស៊ូមតិអំពីសិទ្ធិជនជាតិដើមភាគតិច។ ហិរញ្ញប្បទានកាលពីមុន ត្រូវបានផ្តល់ឲ្យអង្គការដើម្បីភាពញញឹមនៃកុមារ(PSE) ដែលបានផលិតខ្សែភាពយន្តចំនួនបី ពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងទាសភាពកុមារពីទស្សនវិស័យផ្អែកលើសិទ្ធិមនុស្ស។ បច្ចុប្បន្ន ខ្សែភាពយន្តនេះត្រូវបានដាក់បញ្ចាំងនៅទូទាំងប្រទេសកម្ពុជា។

៥៩. នៅក្នុងទិវាសិទ្ធិមនុស្ស ឆ្នាំ២០១២ បុគ្គលិកការិយាល័យ OHCHR បានចូលរួម និងឃ្លាំមើលព្រឹត្តិការណ៍ដែលដឹកនាំដោយសហគមន៍ នៅតាមបណ្តារាជធានី ខេត្តចំនួនប្រាំបី។ មុនពេលទិវានោះ ការិយាល័យ OHCHR បានធ្វើការចែកចាយកញ្ចប់សម្ភារៈផ្សេងៗចំនួន ២០០ កញ្ចប់ ដែលនឹងត្រូវបានប្រើប្រាស់ ដើម្បីប្រារព្ធទិវានេះនៅទូទាំងប្រទេស។ ខ្សែភាពយន្តគំនូរជីវចលខ្មែរមានរយៈពេល ២នាទី ស្តីពីសេរីភាពនៃគំនិត និងការសម្តែងមតិ និងការជួបប្រជុំនៅក្នុងឆុតឆាកនៃទំនាស់ដីធ្លី ត្រូវបានបង្ហោះនៅលើគេហទំព័រ ហើយបន្ទាប់មកទៀត បានបញ្ចាំងនៅក្នុងវេទិកាជាសាធារណៈ និង

ការបណ្តុះបណ្តាលផ្សេងៗ។ ការិយាល័យ OHCHR បានចូលរួមផងដែរ ជាមួយភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ ដើម្បីប្រារព្ធទិវាអន្តរជាតិដទៃផ្សេងទៀត មានដូចជា ទិវាសេរីភាពសារព័ត៌មានពិភពលោក (ជាមួយអង្គការយូណេស្កូ UNESCO) និងយុទ្ធនាការរយៈពេល ១៦ ថ្ងៃ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រីភេទដែលដឹកនាំដោយអង្គការ UN WOMEN ។ ការិយាល័យ OHCHR បានគាំទ្រផងដែរ ដល់ការបោះពុម្ពខិតប័ណ្ណយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីការបោះឆ្នោតថ្នាក់ជាតិ ដែលបានបង្កើតឡើងដោយគណៈកម្មាធិការអាព្យាក្រឹត្យ និងមិនលំអៀង ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (NICFEC) សិទ្ធិស្ត្រីធ្វើការងារដោយសហភាពការងារកម្ពុជា(CLC) និងកម្មវិធីវិទ្យុរយៈពេលមួយខែស្តីពីសិទ្ធិជនពិការ ដោយអង្គការសម្លេងជនពិការភ្នែកដែលមានមូលដ្ឋាននៅខេត្តបាត់ដំបង។

## VII. ស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេស និងការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់

៦០. ក្នុងខែធ្នូ ឆ្នាំ២០១២ ប្រទេសកម្ពុជាបានដាក់របាយការណ៍តាមកាលកំណត់លើកទីពីររបស់ខ្លួន ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលហួសកាលកំណត់ចាប់តាំងពីឆ្នាំ២០០២។ ការិយាល័យ OHCHR បានផ្តល់ការគាំទ្រយ៉ាងទូលំទូលាយដល់រាជរដ្ឋាភិបាលក្នុងការរៀបចំរបាយការណ៍នេះនិងរបាយការណ៍ដទៃផ្សេងទៀតដែលហួសកាលកំណត់។ តាមរយៈរបាយការណ៍ដែលបានដាក់ស្នើនេះ កម្ពុជាបានជម្រះចេញនូវរបាយការណ៍សេសសល់ដែលកកស្ទះដោយមានការជួយឧបត្ថម្ភពីការិយាល័យOHCHR។

៦១. ការិយាល័យ OHCHR បានបន្តគាំទ្រការងាររបស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជានៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់លោកមកកាន់ប្រទេសកម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០១២ និងខែឧសភា ឆ្នាំ២០១៣ ។ សំណើផ្សេងទៀតសម្រាប់បំពេញបេសកកម្មជាផ្លូវការដោយអ្នករាយការណ៍ពិសេសឯទៀត មិនត្រូវបានរាជរដ្ឋាភិបាលទទួលយកនៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះទេ។ អគ្គលេខាធិការ អ.ស.ប ជំរុញលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងពិចារណាផងដែរអំពីការអញ្ជើញអ្នកទទួលបានអាណត្តិនីតិវិធីពិសេសតាមវិស័យដទៃទៀត ដើម្បីទទួលបានអត្ថប្រយោជន៍ពីជំនាញជាក់លាក់របស់ពួកគេ។

៦២. ការិយាល័យ OHCHR បានជួយរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ក្នុងការតាមដានការអនុវត្តដំណើរការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់(UPR) ជុំទីមួយ និងការត្រៀមលក្ខណៈសម្រាប់ការពិនិត្យរបាយការណ៍បន្ទាប់របស់កម្ពុជានៅដើមឆ្នាំ២០១៤។ កិច្ចប្រជុំមួយរបស់សង្គមស៊ីវិលដែលបានឧបត្ថម្ភគាំទ្រដោយការិយាល័យ OHCHR នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣ បាននាំឲ្យមានការបង្កើតក្រុមការងារ ដើម្បីរៀបចំរបាយការណ៍តាមវិស័យសម្រាប់ការដាក់ស្នើទៅក្រុមការងារពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់(UPR)។ តាមការស្នើសុំរបស់រាជរដ្ឋាភិបាល ការិយាល័យ OHCHR បានសហការរៀបចំសិក្ខាសាលាអន្តរក្រសួងមួយ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ដែលបានផ្តោតលើសេចក្តីព្រាងរបាយការណ៍របស់រាជ រដ្ឋាភិបាលសម្រាប់ការពិនិត្យលើកក្រោយទៀត។

---------------------------------------------------